# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សា បឋមភូមិក្នុងខេត្តស្វាយរៀង

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT SECONDARY SCHOOLS IN SVAY RIENG PROVINCE


ដោយ/By

ខូ សុខា/KHO SOKHA


**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ**

**ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**ឆ្នាំសិក្សា ២០១៩-២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សា បឋមភូមិក្នុងខេត្តស្វាយរៀង

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT SECONDARY SCHOOLS IN SVAY RIENG PROVINCE

ដោយ/By

ខូ សុខា/KHO SOKHA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ជំនាន់ទី៣

ឯកទេសៈ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩-២០២០

សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត ឈាង សទ្ធាត

# លិខិតបញ្ជាក់ និងទទួលស្គាល់របស់នាយកវិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខៈ.......✓....... វជអ.

## លិខិតបញ្ជាក់ និងទទួលស្គាល់

**នាយកវិទ្យាស្ថានជាតិអប់រំ**

**សូមបញ្ជាក់ និងទទួលស្គាល់ថាៈ**

លោក **ខូ សុខា** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ **"ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ" ករណីសិក្សាៈ ខេត្តស្វាយរៀង** ស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាល ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សឿង សុវណ្ណា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទសិក្សាស្រាវជ្រាវមានចំណងជើងថា **"ស្ថានភាពនៃការប្រើ-ប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង"** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង ។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០......

**ហត្ថលេខា**

**ខូ សុខា**

# លិខិតបញ្ជាក់

**បណ្ឌិត ឈាង សទ្ធាត** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ខូ សុខា** ជានិស្សិតបញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង**" ប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០.......

**បណ្ឌិត ឈាង សទ្ធាត**

គ្រូឧទ្ទេស

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ៣៣៤ ...ទជអ. ៦០

**លិខិតឧទ្ទេសនាម**

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពានិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី វង្ហា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ធី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ រ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្លួន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន រ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ www.nie.edu.kh

II. **លេខាកត់ត្រា** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប តេនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃ ពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងរដ្ឋ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"
-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ខូ សុខា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំ ។

សូមថ្លែងអំណរគុណជាអនេកចំពោះ៖

– លោកបណ្ឌិត ឈាង សង្វាត សាស្ត្រាចារ្យដឹកនាំ ដែលបានត្រួសត្រាយបង្ហាញផ្លូវ បំផុសស្មារតី ផ្ដល់ជាគំនិតណែនាំ និងបានពិនិត្យ ព្រមទាំងកែសម្រួលលើកិច្ចការស្រាវជ្រាវមួយនេះប្រកបដោយការទទួលខុសត្រូវនិងវិជ្ជាជីវៈខ្ពស់ទាំងខ្លឹមសារ និងរចនាបថ ។

– ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនេះ ក្នុងការផ្ដល់ឱកាសឱ្យមន្ត្រីអប់រំបានអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែម ។

– ឯកឧត្តមនាយក លោកនាយករង លោកស្រីនាយិការង លោក លោកស្រីជាសាស្ត្រាចារ្យ បុគ្គលិក នៃវិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់ បង្រៀនរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ ។

– ឯកឧត្តម លោកគ្រូឧទ្ទេសថ្នាក់ក្រសួងទាំងអស់ដែលបានបង្រៀនប្រកបដោយការយកចិត្តទុកដាក់និងលះបង់ពេលវេលាដ៏មានតម្លៃមកបណ្ដុះបណ្ដាលរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ ។

– លោកនាយកសាលាមធ្យមសិក្សាក្នុងខេត្តស្វាយរៀងទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការឆ្លើយនូវកម្រងសំណួរ ។

– លោកឪពុក ខូ ខឿន និងអ្នកម្ដាយ ឡី យ៉យ ជាអ្នកមានគុណដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់ឧត្ដមសិក្សាដោយមិនគិតពីការលំបាក នឿយហត់ ព្រមទាំងតស៊ូគ្រប់បែបយ៉ាងដើម្បីកូនទទួលបានចំណេះដឹង និងមានអនាគតល្អដូចថ្ងៃនេះ ។

– លោកស្រី នន់ ស្រីអូន ជាឧត្តមភរិយា និងបុត្រាទាំងអស់របស់ខ្ញុំ ដែលបានជួយជ្រោមជ្រែងទាំងផ្នែកថវិកា ស្មារតី និងការលើកទឹកចិត្តឱ្យខ្ញុំបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ។

ជាចុងបញ្ចប់ខ្ញុំបាទសូមគោរពជូនពរ លោក លោកស្រី ជាសាស្ត្រាចារ្យ និងបុគ្គលិកវិទ្យាស្ថានជាតិអប់រំ និងឯកឧត្តម លោក លោកស្រីទទួលបានសេចក្តីសុខ មានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួនទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មូលន័យសង្ខេប

ការស្រាវជ្រាវនេះ ផ្តោតទៅលើស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅតាមសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង ដោយមានគោលបំណងសំខាន់ៗពីរគឺ ទីមួយសិក្សាពីស្ថានភាពនៃគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន និងទីពីរស្វែងយល់ពីបញ្ហាប្រឈមនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន និងដំណោះស្រាយនានាដែលនាយកសាលាបានប្រើប្រាស់ដើម្បីឱ្យសាលារៀនដំណើរការបានល្អ ។ អ្នកស្រាវជ្រាវបានកំណត់យកនាយកសាលាចំនួន ៧៤នាក់ របស់សាលាមធ្យមសិក្សានៅក្នុងខេត្តស្វាយរៀង ដែលមានសិស្សថ្នាក់ទី៧ ដល់ទី៩ ។ ឧបករណ៍ស្រាវជ្រាវដែលប្រើប្រាស់ក្នុងស្រាវជ្រាវនេះជាកម្រងសំណួរ ដែលត្រូវបានរៀបចំឡើងសម្រាប់នាយក ដែលត្រូវឆ្លើយតបនឹងសំណួរស្រាវជ្រាវទាំងពីរដោយមានទាំងសំណួរទម្រង់បិទនិងសំណួរទម្រង់បើក ។ ការវិភាគទិន្នន័យបង្ហាញជាតារាង ជាក្រាប បង្ហាញជាតម្លៃមធ្យម(M) គម្លាតស្តង់ដារ(SD) និងផ្តោតលើការបកស្រាយលើសំណួរទម្រង់បើកដោយការធ្វើចំណាត់ថ្នាក់ជាក្រុមដោយផ្អែកទៅលើទស្សនៈ និងចម្លើយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នារួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុម នីមួយៗ។

ការស្រាវនេះបានរកឃើញថាស្ថានភាពនៃការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀនមានលក្ខណៈល្អដោយនាយកសាលាបានអនុវត្តការគ្រប់គ្រងគ្រូបង្រៀន តាមវិធីសាស្រ្តដែលកំណត់ដោយស្តង់ដារនាយកសាលា រីឯការប្រើប្រាស់និងបែងចែកគ្រូបង្រៀនកម្រិតមូលដ្ឋាននៅតាមអនុវិទ្យាល័យ/វិទ្យាល័យនានានៅទូទាំងខេត្តនាពេលបច្ចុប្បន្នមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដោយចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានដែលកំពុងប្រើប្រាស់នៅសាលាគោលដៅទូទាំងខេត្តស្វាយរៀងគឺមានការលើសចំនួន ១៣៧នាក់លើមុខវិជ្ជាជីវៈវិទ្យា ផែនដីនិងបរិស្ថានវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌-ពលរដ្ឋ និងអប់រំកាយកីឡា តែការលើសនេះគឺលើសតែសាលាដែលនៅទីប្រជុំជន ចំណែកឯសាលានៅជនបទមានការខ្វះគ្រូបង្រៀន។ ចំនួនសិស្ស ថ្នាក់ មិនទាន់អនុវត្តបានតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។ ការ

ប្រើប្រាស់គ្រូបង្រៀនខុសជំនាញឯកទេស និងខុសកម្រិតកំពុងត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈមនៃការលើសគ្រូ និងខ្វះគ្រូបង្រៀនដែលធ្វើឱ្យគុណភាពនៃការអប់រំនៅមានកម្រិត។

# មាតិកា

**លិខិតបញ្ជាក់ និងទទួលស្គាល់របស់នាយកវិទ្យាស្ថានជាតិអប់រំ**....................................i
**សេចក្តីអះអាងរបស់បេក្ខជន** ................................................................................ii
**លិខិតបញ្ជាក់**.................................................................................................iii
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ...................................iv
**សេចក្តីថ្លែងអំណរគុណ**.......................................................................................vi
**មូលន័យសង្ខេប**..............................................................................................viii
**បញ្ជីតារាង**.......................................................................................................xiii
**បញ្ជីរូបភាព** .....................................................................................................xv
**ជំពូកទី១៖ សេចក្តីផ្តើម**.........................................................................................1

១.១. សាវតារ ....................................................................................................1
១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ .......................................................................2
១.៣. គោលបំណងនៃការស្រាវជ្រាវ ........................................................................3
១.៤. សំណួរស្រាវជ្រាវ .........................................................................................4
១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ........................................................5

**ជំពូកទី២៖ រំលឹកទ្រឹស្តី**..........................................................................................7

២.១. និយមន័យពាក្យគន្លឹះ ..................................................................................7
២.២. និយាមប្រើបុគ្គលិកអប់រំ...............................................................................8
២.២.១ ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ និងម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ..8
២.២.១.២ ការកំណត់ម៉ោងបំពេញកាងាររបស់បុគ្គលិកអប់រំ ..............................................8
២.២.១.៣ ម៉ោងប្រចាំសប្តាហ៍សម្រាប់ការបង្រៀនក្នុងថ្នាក់ និងការបំពេញភារកិច្ចផ្សេងៗរបស់បុគ្គលិកអប់រំនៅមធ្យមសិក្សាបឋមភូមិ ............................................................9
២.២.២ និយាមប្រើបុគ្គលិកអប់រំតាមគ្រឹះស្ថានសិក្សាសាធារណៈ ........................................9
២.២.២.១ និយាមប្រើបុគ្គលិកបង្រៀន ..........................................................................9
២.២.២.២ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀននៅមធ្យមសិក្សា ...........................10

២.៣. សេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀន 11
២.៤. របាយមុខវិជ្ជានិងម៉ោងសិក្សា 18
២.៥. តួនាទី និងភារកិច្ចនាយកសាលានៅកម្ពុជា 19
២.៦ គោលនយោបាយស្តីពីគ្រូបង្រៀន 22
២.៦.១ ចក្ខុវិស័យ 22
២.៦.២ គោលបំណង 22
២.៦.៣ គោលដៅ 22
២.៦.៤ យុទ្ធសាស្រ្ត 22
២.៧ បញ្ហាប្រឈមនៃការអប់រំនៅតាមគ្រឹះស្ថានមធ្យមសិក្សា 25
២.៧.១ បញ្ហាប្រឈមពាក់ព័ន្ធការអនុវត្តគោលនយោបាយ 25
២.៧.២ បញ្ហាប្រឈមពាក់ព័ន្ធគ្រឹះស្ថានសិក្សា 26
២.៨ ឫសគល់នៃបញ្ហាក្នុងការអប់រំនៅកម្ពុជា 28
២.៨.១. សេវានៅក្នុងសាលារៀនមានមិនគ្រប់ 28
២.៨.២. សេវានៅក្នុងសាលារៀនមិនដំណើការ 28
២.៨.៣. សេវានៅក្នុងសាលារៀនមិនឆ្លើយតបនឹងតម្រូវការ 28
២.៨.៤. ខ្វះការវាយតម្លៃ និងកែលម្អរសេវា 29
២.៩. យុទ្ធសាស្រ្តក្នុងការដោះស្រាយបញ្ហា 29
**ជំពូកទី៣៖ វិធីសាស្រ្តស្រាវជ្រាវ** 31
៣.១. គម្រោងវិភាគ 31
៣.២. ការប្រមូលទិន្នន័យ 31
៣.៣. ឧបករណ៍ស្រាវជ្រាវ 31
៣.៣.១ កម្រិតចង្អុលបង្ហាញ 32
៣.៤. ការជ្រើសរើសភាគសំណាក 33
៣.៥. ការវិភាគទិន្នន័យ 33
**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** 35

៤.១. ការវិភាគទិន្នន័យលើកម្រងសំណួរ ....35
៤.១.១ ព័តមានទូទៅរបស់អ្នកចូលរួម ....35
៤.១.២ ទីតាំងសាលារៀន ....35
៤.១.៣ ការកំណត់ពីតម្រូវការ ....36
៤.១.៤ ទស្សនៈរបស់គណៈគ្រប់គ្រងលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន....47
៤.១.៥ បញ្ហាប្រឈមនិងដំណោះស្រាយរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន....52
៤.១.៦ មតិយោបល់បន្ថែមរបស់នាយកសាលាលើការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន....54
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**....55
៥.១. សេចក្តីសន្និដ្ឋាន ....55
៥.២. សំណូមពរ ....55
**ឯកសារយោង**....58
**ឧបសម្ព័ន្ធ ក**....60
**ឧបសម្ព័ន្ធ ខ**....64
**ឧបសម្ព័ន្ធ គ**....68

# បញ្ជីតារាង


តារាង២.១៖ ប្រភេទគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ........ 8

តារាង២.២៖ ម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ ........ 8

តារាង២.៣៖ ម៉ោងប្រចាំសប្ដាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ........ 9

តារាង២.៤៖ និយាមប្រើប្រាស់បុគ្គលិកបង្រៀន ........ 9

តារាង២.៥៖ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀននៅមធ្យមសិក្សា ........ 10

តារាង២.៦៖ មុខវិជ្ជាកម្មវិធីសិក្សាជាតិ(កម្មវិធីសិក្សាគោលឆ្នាំ២០០៦) ........ 18

តារាង២.៧៖ មុខវិជ្ជាសិក្សាតាមក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦ ........ 18

តារាង៣.១៖ ពិន្ទុមធ្យមភាគនៃសូចនាករ ........ 32

តារាង៣.២៖ ចំនួនសំណាក ........ 33

តារាង៤.១៖ ចំនួននាយកគិតតាមភេទ អាយុ និងរយៈពេលនៃបទពិសោធន៍ជានាយក ........ 35

តារាង៤.២៖ ទីតាំងសាលារៀនរបស់នាយកសាលាដែលបំពេញកម្រងសំណួរ ........ 36

តារាង៤.៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែង ........ 37

តារាង៤.៤៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែង(តាមក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦) ........ 39

តារាង៤.៥៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី១ ........ 41

តារាង៤.៦៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី២ ........ 41

តារាង៤.៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី៣ ........ 42

តារាង៤.៨៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី៤ ........ 43

តារាង៤.៩៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី៥ ........ 44

តារាង៤.១០៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងក្រុងទី៦ ........ 45

តារាង៤.១១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី៧ ........ 46

តារាង៤.១២៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែងស្រុកទី៨ ........ 46

តារាង៤.១៣៖ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត ...................................................... 47
តារាង៤.១៤៖ កម្រិតនៃការអនុវត្តសកម្មភាពលម្អិតលើផ្នែកគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន .......... 48
តារាង៤.១៥៖ កម្រិតនៃការអនុវត្តសកម្មភាពលើការប្រើប្រាស់ និងការគ្រប់គ្រងគ្រូបង្រៀន ............... 50

# បញ្ជីរូបភាព

ក្រាបទី១៖ ចំនួនគ្រូតាមមុខវិជ្ជា តាមតម្រូវការ និងមានស្រាប់ .................................................... 38

ក្រាបទី២៖ ចំនួនគ្រូតាមមុខវិជ្ជា តាមតម្រូវការ(តាមកម្មវិធីសិក្សាឆ្នាំ២០១៦) និងមានស្រាប់............ 40

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១. សាវតារ

ការអប់រំ និងការបណ្តុះបណ្តាលគឺជាយុទ្ធសាស្ត្រសំខាន់ជាងគេ ដើម្បីសម្រេចគោលបំណងនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ។ ភស្តុតាងនៃការស្រាវជ្រាវ និងបទពិសោធន៍ជាច្រើនពីប្រទេសផ្សេងៗក្នុងសកលលោកបានបង្ហាញពីអានុភាពនៃការអប់រំ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ ជួយមនុស្សឱ្យទទួលបានការងារសមរម្យ បង្កើនប្រាក់ចំណូលរបស់ពួកគេ និងបង្កើនផលិតភាព ដែលជួយនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច ។ ការអប់រំគឺជាមធ្យោបាយដែលមានអានុភាពបំផុតដើម្បីសម្រេចសមភាពយេនឌ័រ លើកកម្ពស់សុខភាពប្រជាពលរដ្ឋ ជំរុញលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស បង្កើនភាពជាពលរដ្ឋសកល ជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)

គ្រូបង្រៀនដើរតួនាទីសំខាន់ណាស់ ព្រោះពួកគេជាអ្នកផលិតធនធានមនុស្ស សម្រាប់ឱ្យទៅបម្រើការងារនៅគ្រប់វិស័យក្នុងសង្គម ហើយក៏ជាវិស្វករនៃព្រលឹងដែលរដ្ឋបានផ្តល់ទំនុកចិត្តឱ្យបង្រៀន និងអប់រំយុវជន យុវនារី ដែលជាសសរទ្រូងដ៏មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះគ្រួសារ និងសង្គមជាតិទាំងមូល។ អនាគតប្រទេសជាតិអាស្រ័យទាំងស្រុងទៅលើគ្រូបង្រៀន។ ប្រទេសជាតិទទួលបានការរីកចម្រើន ឬមានភាពទន់ខ្សោយ អាស្រ័យទៅលើគុណភាពនៃការអប់រំ ជាពិសេសអាស្រ័យទៅលើធនធានមនុស្សដែលគ្រូបង្រៀនគ្រប់កម្រិត និងគ្រប់វិស័យផលិតបាន។ វិស្វករសំណង់ម្នាក់បំពេញភារកិច្ចរបស់ខ្លួនមិនបានល្អ ធ្វើការខ្ជីខ្ជា ការខូចខាតមានតែសម្ភារប៉ុណ្ណោះ ឬបើធ្ងន់ធ្ងរជាងនេះទៅទៀតវិនាសតែគ្រួសារមួយប៉ុណ្ណោះ។ ផ្ទុយទៅវិញគ្រូបង្រៀនម្នាក់ ដែលខ្វះចំណេះដឹង ខ្វះសីលធម៌ ហើយបំពេញភារកិច្ចរបស់ខ្លួនមិនបានទទួលជោគជ័យ ផ្តល់ការអប់រំគ្មានគុណភាព ឬផលិតធនធានមនុស្សមិនទទួលបានសម្បទាពេញលេញ អ្នកដែលត្រូវទទួលផលវិបាកអាក្រក់គឺមនុស្សជាតិទាំងមូល ពិសេសគឺយុវជន យុវនារីដែលជាសរសរទ្រូងរបស់

ប្រទេសជាតិ ហើយប្រទេសជាតិទាំងមូលនឹងត្រូវទទួលផលវិបាកអាក្រក់ជាក់ជាមិនខាន (អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ២០១៨)។

ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ ទទួលបានការលើកទឹកចិត្ត ទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុខវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ និងស្រឡាញ់ការងារបង្រៀន និងសិស្សានុសិស្សរបស់ខ្លួន ។ គ្រូបង្រៀននឹងទទួលបានការគាំទ្រជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង សមត្ថភាពសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស(ក្រសួងអប់រំ យុវជន និងកីឡា ២០១៩) ។

គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងមានទេពកោសល្យក្នុងការបង្ហាត់បង្រៀន គឺជាកត្តាដ៏សំខាន់បំផុតក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយអប់រំរបស់កម្ពុជាដែលរួមមាន ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក៏ដូចជាធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ជាដើម(ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨)។ ពិសេសជាងនេះទៅទៀត បើគ្មានគ្រូបង្រៀននោះទេ ក៏គ្មានការអប់រំពេញមួយជីវិត ហើយក៏គ្មានសង្គមពុទ្ធិ និងវិបុលភាពនោះដែរ។ ដើម្បីទៅដល់គោលដៅនេះទាមទារឱ្យការបែងចែកនិងគ្រប់គ្រងគ្រូបង្រៀនមានប្រសិទ្ធភាព ព្រោះវាជាកូនសោរគន្លឹះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែទម្រង់ជាច្រើន ដើម្បីធានានូវការពង្រឹងគុណភាពអប់រំឱ្យសមស្របទៅនឹងនិន្នាការអប់រំក្នុងតំបន់ និងពិភពលោកនាសតវត្សន៍ទី២១ ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

គ្រូបង្រៀនគឺជាបេះដូងនៃដំណើរការសិក្សា។ ពួកគេជះឥទ្ធិពលយ៉ាងខ្លាំងទៅលើគុណភាពនៃការអប់រំដែលកុមារទទួលបាននៅសាលារៀននិងលទ្ធផលនៃការសិក្សារបស់ពួកគេ ។ ការគ្រប់គ្រងគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាពមានសារៈសំខាន់ណាស់សំរាប់ភាពជោគជ័យនៃប្រព័ន្ធអប់រំមួយ ។ ទោះជាយ៉ាង-ណាក៏ដោយរដ្ឋាភិបាលបានជួបនឹងបញ្ហាប្រឈមកាន់តែខ្លាំងឡើងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗលើការគ្រប់គ្រង

បុគ្គលិកបង្រៀនរបស់ពួកគេ ។ ដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំយ៉ាងឆាប់រហ័សប្រទេសនានាបានដាក់ប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ខ្លួនឱ្យស្ថិតក្នុងស្ថានភាពតានតឹង ។ ក្រសួងនានាត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់គ្រូដែលកំពុងកើនឡើង ស្របពេលជាមួយគ្នានេះដែរព្យាយាមជានាបាននូវគុណភាពដូចគ្នា ។ បន្ថែមលើបញ្ហាប្រឈមទាក់ទងនឹងការផ្គត់ផ្គង់ និងការបណ្តុះបណ្តាលគ្រូនៅប្រទេសនានាត្រូវដោះស្រាយបញ្ហាទាក់ទងនឹងការបែងចែកនិងការប្រើប្រាស់គ្រូបង្រៀនដោយសមធម៌នៅទូទាំងតំបន់ផ្សេងៗគ្នា។ អវត្តមានរបស់គ្រូ ការយកចិត្តទុកដាក់ខ្ពស់ និងការលើកទឹកចិត្តទាបគឺជាបញ្ហាមួយដែលអ្នករៀបចំផែនការអប់រំត្រូវលាតត្រដាងតាមរបៀបមួយ ឬ ផ្សេងទៀតនៅក្នុងស្ទើរតែគ្រប់ប្រទេសទាំងអស់នៅជុំវិញពិភពលោក ( http://www.iiep.unesco.org/en/our-mission/teacher-management ) ។

ចាប់តាំងពីឆ្នាំ២០១៤មកក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់វិស័យអប់រំកម្ពុជាមហាជនបានងាកមកចាប់អារម្មណ៍ទៅលើគុណតម្លៃរបស់បុគ្គលិកសិក្សា ឬអាជីពជាគ្រូបង្រៀនគ្រប់កម្រិតសិក្សាទូទាំងប្រទេស ។ ជាលទ្ធផលធ្វើឱ្យការសិក្សាអប់រំមានលក្ខណៈល្អប្រសើរបន្តិចម្តងៗ ។ ទន្ទឹមពេលជាមួយគ្នានេះក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតកម្មវិធីវិក្រឹតការជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំនៅតាមបណ្តាអនុវិទ្យាល័យនានាក្នុងទូទាំងប្រទេស ។ ប៉ុន្តែបើទោះបីជាមានការធ្វើវិក្រឹតការយ៉ាងដូច្នេះក្តី ក៏សមត្ថភាពអ្នកគ្រប់គ្រងទាំងនោះនៅមានកម្រិត និងមិនទាន់ឆ្លើយតបទៅនឹងការកែទម្រង់របស់ក្រសួងនៅឡើយ ជាហេតុបណ្តាលឱ្យស្ថានភាពនៃការប្រើប្រាស់ និងបែងចែកគ្រូបង្រៀនអាចជួបប្រទះនូវបញ្ហាប្រឈមហើយក៏ជាកត្តាមួយដែលធ្វើឱ្យគុណភាពនៃការអប់រំធ្លាក់ចុះខ្លះផងដែរ ។ រហូតមកដល់ពេលនេះ នៅមិនទាន់មានការសិក្សាណាមួយបានបង្ហាញពីស្ថានភាពនៃការប្រើប្រាស់គ្រូនៅអនុវិទ្យាល័យនៅឡើយ ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗចំនួនពីរគឺ៖

១. សិក្សាពីស្ថានភាពនៃការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តស្វាយរៀង

២. ស្វែងយល់ពីបញ្ហាប្រឈមដែលនាយក/នាយិកាជួបប្រទះនៅក្នុងការប្រើប្រាស់គ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តស្វាយរៀង និងដំណោះស្រាយលើបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀនរបស់ពួកគាត់ ។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ អ្នកស្រាវជ្រាវត្រូវដោះស្រាយលើសំណួរចំនួន២គឺ៖

១. តើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង មានស្ថានភាពយ៉ាងដូចម្ដេចខ្លះ ?

២. តើនាយក/នាយិកា ជួបបញ្ហាប្រឈមអ្វីខ្លះនៅក្នុងការប្រើប្រាស់គ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ ? តើពួកគាត់មានដំណោះស្រាយយ៉ាងដូចម្ដេចចំពោះបញ្ហាប្រឈមទាំងនោះ ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងបង្ហាញអ្នកអានពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលាក្នុងសាលាមធ្យមសិក្សាបឋមភូមិ ដោយលទ្ធផលនឹង៖

- បង្ហាញនូវចំនួនគ្រូលើស ឬខ្វះនៅតាមសាលាមធ្យមសិក្សាបឋមភូមិនៅទូទាំងខេត្ត និងតាមស្រុកនីមួយៗក្នុងខេត្តស្វាយរៀង ។
- បង្ហាញពីកម្រិតនៃការរៀបចំចំនួនសិស្សតាមថ្នាក់ធៀបទៅនិងនិយាមគរុកោសល្យ ។
- បង្ហាញពីកម្រិតនៃការប្រើប្រាស់គ្រូតាមជំនាញឯកទេស និងសមត្ថភាព
- បង្ហាញមូលហេតុទាំងឡាយណាដែលធ្វើឱ្យសាលាខ្វះលើសគ្រូ ហើយសាលាខ្វះទៀតខ្វះគ្រូ
- បង្ហាញពីទស្សនៈរបស់នាយក នាយិកា ក្នុងការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន
- បង្ហាញអំពីបញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រើប្រាស់គ្រូតាមសាលាមធ្យមសិក្សាកម្រិតបឋមភូមិនានាក្នុងខេត្តស្វាយរៀង
- ផ្ដល់នូវយុទ្ធសាស្ត្រក្នុងការបែងចែកគ្រូប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការ

- ផ្តល់នូវធាតុចូលសម្រាប់កំណត់គោលនយោបាយគ្រប់គ្រងនិងបែងចែកគ្រូបង្រៀន ឱ្យមានប្រសិទ្ធភាព
- កសាងឯកសារគោលសម្រាប់ការងារស្រាវជ្រាវបន្ត ។

អ្នកស្រាវជ្រាវសង្ឃឹមថា ស្នាដៃស្រាវជ្រាវនេះអាចជាឯកសារជំនួយ ឬជាទុនដល់អ្នកសិក្សាជំនាន់ក្រោយ ក្នុងការក្រេបយកចំណេះដឹងទាក់ទងនឹងការប្រើប្រាស់គ្រូបង្រៀន ឬអាចទុកជាឯកសារគំរូសម្រាប់អ្នកស្រាវជ្រាវក្រោយៗទៀត ។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សានេះ ផ្តោតទៅលើស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនដែលមានគុណវុឌ្ឍិនៅតាមសាលាមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ មិនផ្តោតទៅលើអ្វីក្រៅពីនេះឡើយ។ ការសិក្សាស្រាវជ្រាវនេះ នៅតាមសាលាមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ និងវិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧, ៨ និងទី៩)ក្នុងខេត្តស្វាយរៀង ចំនួន៧៤សាលា (ក្រុងចំនួន២ និងស្រុកចំនួន៦) អ្នកស្រាវជ្រាវបានផ្តល់ជាកម្រងសំណួរបែបគុណវិស័យ និងបរិមាណវិស័យ សម្រាប់សម្ភាស នាយក/នាយិកាសាលាចំនួន៧៤នាក់ក្នុងខេត្តទាំងមូល។ កម្រងសំណួរខាងលើបានផ្តោតទៅលើ៣ចំនុច៖ ១) ការកំណត់ពីតម្រូវការ, ២) ទស្សនៈរបស់នាយក នាយិកាលើការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន, ៣) បញ្ហាប្រឈម និងដំណោះស្រាយនានារបស់នាយក នាយិកា ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងនិក្ខេបបទនេះ អ្នកស្រាវជ្រាវបានរៀបចំជាចំណុចសំខាន់ៗ និងដាក់ជាជំពូកដើម្បីឱ្យការសិក្សាស្រាវជ្រាវមានភាពងាយស្រួល ច្បាស់លាស់ និងងាយយល់ ។ ក្នុងឯកសារស្រាវជ្រាវនេះរួមមាន ៥ ជំពូកសំខាន់ៗ ហើយក្នុងនោះ ក៏មានចំណុចតូចៗផ្សេងទៀតផងដែររួមមាន៖

ជំពូកទី១ ជាសេចក្តីផ្តើមមានបង្ហាញពីសាវតារ បញ្ហានៃការស្រាវជ្រាវ វត្ថុបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃ

ការស្រាវជ្រាវ ។

ជំពូកទី២ ជាការរំលឹកទ្រឹស្តីមានបកស្រាយអំពី និយមន័យពាក្យគន្លឹះ និងលើកយកទ្រឹស្តីដែលពាក់ព័ន្ធមកបង្ហាញដូចជាសេចក្តីណែនាំស្តីពីការប្រើប្រាស់គ្រូបង្រៀន ប្រសិទ្ធភាពនៃការដឹកនាំនិងវាយតម្លៃ ។

ជំពូកទី៣ ជាវិធីសាស្ត្រនៃការស្រាវជ្រាវដែលរៀបរាប់ពីគម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ ដែលជាជំហាននៃការប្រើប្រាស់ទិន្នន័យដ៏មានប្រសិទ្ធភាព ដើម្បីឱ្យកិច្ចការស្រាវជ្រាវមានលក្ខណៈលម្អិត និងក្បោះក្បាយ ។

ជំពូកទី៤ មានបង្ហាញលទ្ធផលនៃការស្រាវដែលឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរក្នុងជំពូកទី១ ។ លទ្ធផលនៃការស្រាវជ្រាវបង្ហាញពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន នៅតាមអនុវិទ្យាល័យ/វិទ្យាល័យនានាក្នុងខេត្តស្វាយរៀង បញ្ហាប្រឈមដែលសាលារៀននីមួយបានជួបប្រទះនិងដំណោះស្រាយនានាដែលនាយកសាលាបានប្រើប្រាស់ ព្រមទាំងពិភាក្សាលើទិន្នន័យធៀបទៅនឹងទ្រឹស្តីផ្សេងៗ ។

ជំពូកទី៥ ជាជំពូកចុងក្រោយបង្ហាញពីការសន្និដ្ឋាន សំណូមពរ និងអនុសាសន៍ ផ្សេងៗរបស់អ្នកស្រាវជ្រាវទុកសម្រាប់អ្នកស្រាវជ្រាវបន្តក្រោយៗទៀត ។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

ដើម្បីទទួលបាននូវឯកសារក៏ដូចជាធនធានដែលពាក់ព័ន្ធនិងប្រធានបទស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានស្វែងរកឯកសារតាមប្រភពជាច្រើនដូចជាតាមសៀវភៅដែលបានបោះពុម្ពរួច(Hard Copy) លិខិតបទដ្ឋានគតិយុត្តនានា ស្រាវជ្រាវតាមបណ្តាញអ៊ិនធឺណិត(Online sources) ។ ជំពូកនេះដកស្រង់និងរៀបរាប់នូវទ្រឹស្តីសំខាន់ៗដែលពាក់ព័ន្ធទៅលើគ្រូបង្រៀន ការគ្រប់គ្រងគ្រូបង្រៀន ការប្រើប្រាស់គ្រូបង្រៀន និយាមប្រើប្រាស់គ្រូបង្រៀននៅតាមសាលារៀន ។

## ២.១. និយមន័យពាក្យគន្លឹះ

**ស្ថានភាព**គឺទីតាំងស្ថិតនៅពិតប្រាកដ, អាកប្បកិរិយា, ហេតុភេទ, ដំណើរទំនង, បែបបទ, ដើងការ, ដំណើរការណ៍ដែលប្រព្រឹត្តទៅ (ជួន ណាត ១៩៦៧)។

**ការប្រើប្រាស់**(Utilization) គឺជាការប្រើរបស់អ្វីមួយតាមរបៀបដែលមានប្រសិទ្ធភាព នេះបើយោងតាម Cambridge Dictionary (2020) ។

**គ្រូ** គឺជាអ្នកដែលមានចិត្តធូន់ អ្នកដែលគួរគេគោរពគឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗដល់សិស្ស (ជួន ណាត ១៩៦៧)។ **គ្រូបង្រៀន**សំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជន ដែលមានអាជ្ញាប័ណ្ណអប់រំ នេះបើយោងតាមមាត្រាទី៤ នៃអនុក្រឹត្យលេខ ១២៦. អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ។ មាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ស្តីពីលក្ខន្តិកៈដោយឡែកនៃគ្រូកម្រិតមូលដ្ឋានបានចែងថាក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡាប្រមូលផ្តុំគ្រប់មន្ត្រីបច្ចេកទេសខាងគរុកោសល្យ និងបច្ចេកទេសផ្សេងទៀត ដែលបានបណ្តុះបណ្តាល និងបម្រើការនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ បច្ចេកទេស និងអង្គភាពជំនាញថ្នាក់កណ្តាល និងខេត្តក្រុងនៃក្រសួងអប់រំ យុវជន និងកីឡា ។

## ២.២. និយាមប្រើបុគ្គលិកអប់រំ

ដើម្បីធ្វើឱ្យប្រសើរឡើងលើការងារគ្រប់គ្រង និងការបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ ដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋបាល និងនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំប្រកបដោយគុណភាពស្របទៅនឹងបរិបទនៃការអប់រំបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីណែនាំលេខ ២០អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ ស្តីពីនិយាមប្រើបុគ្គលិកអប់រំ ។

### ២.២.១ ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ និងម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ

២.២.១.១ ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ

តារាង២.១៖ ប្រភេទគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ

| គ្រឹះស្ថានសិក្សា | សាលាតូច | សាលាមធ្យម | សាលាធំ |
|---|---|---|---|
| មធ្យមសិក្សា | តិចជាងឬស្មើ ២០ ថ្នាក់ | ចាប់ពី២១ ដល់ ៤០ ថ្នាក់ | ចាប់ពី ៤១ ថ្នាក់ឡើង |

### ២.២.១.២ ការកំណត់ម៉ោងបំពេញកាងាររបស់បុគ្គលិកអប់រំ

តារាង២.២៖ ម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ

| ប្រភេទគ្រឹះស្ថានសិក្សាសាធាណៈ | ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ ក្នុងមួយសប្តាហ៍ | ចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀនឱ្យគ្រប់៤០ម៉ោងក្នុងមួយសប្តាហ៍ |
|---|---|---|
| សាលារៀនចំណេះទូទៅ | | |
| មធ្យមសិក្សាបឋមភូមិ | ១៨ ម៉ោង | ២២ ម៉ោង |

**២.២.១.៣ ម៉ោងប្រចាំសប្តាហ៍សម្រាប់ការបង្រៀនក្នុងថ្នាក់ និងការបំពេញភារកិច្ចផ្សេងៗរបស់បុគ្គលិកអប់រំនៅមធ្យមសិក្សាបឋមភូមិ**

តារាង២.៣៖ ម៉ោងប្រចាំសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ

| ល.រ | ភារកិច្ចដែលត្រូវបំពេញ | អនុវិទ្យាល័យ |
|---|---|---|
| ក | ម៉ោងកំណត់បង្រៀនសិស្ស/និស្សិតក្នុងថ្នាក់ | ១៨ |
| | ក.១ បង្រៀនសុទ្ធសាធ | ១៨ |
| | ក.២ បង្រៀន + ទទួលបន្ទុកថ្នាក់ | ១៤ |
| | ក.៣ បង្រៀន + ប្រធានក្រុមបច្ចេកទេស | ១៦ |
| | ក.៤ បង្រៀន + ទទួលបន្ទុកថ្នាក់ +ប្រធានក្រុមបច្ចេកទេស | ១២ |
| ខ | ម៉ោងបំពេញការងារគាំទ្រការបង្រៀន | ២២ |
| គ | ម៉ោងបំពេញការងាររបស់គ្រូទទួលបន្ទុកថ្នាក់ | ៤ |
| ឃ | ម៉ោងបំពេញការងាររបស់ប្រធានក្រុមបច្ចេកទេស | ២ |
| | សរុប | ៤០ |

**២.២.២ និយាមប្រើបុគ្គលិកអប់រំតាមគ្រឹះស្ថានសិក្សាសាធារណៈ**

**២.២.២.១ និយាមប្រើបុគ្គលិកបង្រៀន**

តារាង២.៤៖ និយាមប្រើប្រាស់បុគ្គលិកបង្រៀន

| គ្រឹះស្ថានសិក្សាសាធារណៈ | និយាមប្រើចំនួនគ្រូ-សិស្ស | |
|---|---|---|
| | និយាមថ្នាក់ - គ្រូបង្រៀន | ផលធៀប សិស្ស-ថ្នាក់ |
| មធ្យមសិក្សាបឋមភូមិ | ១ / ១.៨៣៣ | ៤០- ៥០ |

### ២.២.២.២ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀននៅមធ្យមសិក្សា

តារាង២.៥៖ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀននៅមធ្យមសិក្សា

| តួនាទី និងភារកិច្ច | សាលាតូច តិចជាងឬស្មើ ២០ ថ្នាក់ | | | សាលាមធ្យម ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | | សាលាធំ ចាប់ពី ៤១ ថ្នាក់ឡើង | |
|---|---|---|---|---|---|---|---|
| | ៦ | ៧-១៤ | ១៥-២០ | ២១-២៩ | ៣០-៤០ | ៤១-៦០ | ៦១-៨០+ |
| នាយក | ១ | ១ | ១ | ១ | ១ | ១ | ១ |
| នាយករង | | ១ | ២ | ២ | ២ | ៣ | ៣ |
| លេខាធិការ | ១ | ១ | ១ | ១ | ២ | ២ | ២ |
| បណ្ណារក្ស | | ១ | ២ | ២ | ២ | ៣ | ៣ |
| បេឡា | | | | ១ | ១ | ១ | ១ |
| គណនេយ្យ | | ១ | ១ | ១ | ១ | ១ | ១ |
| អ្នកទទួលបន្ទុកយុវជន | | | ១ | ១ | ១ | ២ | ២ |
| អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍ (បើមានសម្ភារៈនិងដំណើរការ) | | ២ | ២ | ៣ | ៣ | ៣ | ៤ |
| បុគ្គលិក ឬឆ្មាំ | | | | | | | ២ |
| អន្តេវាសិកដ្ឋាន សិស្ស ៦០នាក់ អ្នកគ្រប់គ្រងម្នាក់ | | | | | | | |
| អ្នកដាំស្លសិស្ស៥០នាក់អ្នកដាំស្ល១នាក់ | | | | | | | |
| សរុប | ២ | ៧ | ១០ | ១២ | ១៣ | ១៦ | ១៩ |

## ២.៣. សេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀន

សេចក្តីណែនាំលេខ៥៣ អយក.សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងគ្រូបង្រៀន បានកំណត់ថាដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ ពីរពេល និងគ្រូបង្រៀនថ្នាក់គួប ចាប់ពីឆ្នាំសិក្សា ២០១៩ - ២០២០ ក្រសួង អប់រំ យុវជន និងកីឡាដាក់ចេញនូវវិធានការដូចខាងក្រោម៖

២.៣.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ

- ❖ គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំតាមសេចក្តីណែនាំលេខ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ
    - ○ នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាងឬស្មើ៣ថ្នាក់
    - ○ ចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន

❖ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យនិងរៀបចំស្វ័យប្រកាសសាលារៀនដែលមានតម្រូវការគ្រូបង្រៀនតាមប្រភេទក្របខណ្ឌនិងមុខវិជ្ជាជំនាញនិងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខណ្ឌឱ្យទៅដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន

- ❖ គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ
- ❖ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សទាំងនៅថ្នាក់ជាតិ និងរាជធានីខេត្ត
- ❖ ចុះពិនិត្យការអនុវត្តនិយាម (ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន)

❖ ក្រសួងនឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្តល់ក្របខណ្ឌបណ្តោះអាសន្ន

❖ ក្រសួងនឹងពិនិត្យស្នើគោលការណ៍ផ្តល់បៀវត្សមូលដ្ឋានដល់គរុសិស្ស គរុនិស្សិត បន្ទាប់ពីបានប្រឡងជាប់។

២.៣.១.១ ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា

❖ គ្រឹះស្ថានសិក្សានីមួយៗត្រូវធ្វើការវិភាគនិងព្យាករអំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខណ្ឌនិងមុខវិជ្ជាជំនាញឱ្យបានច្បាស់លាស់មុននឹងលើកសំណើសុំគ្រូបង្រៀនបន្ថែម រួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនពីរថ្នាក់ពីរពេល ។ល។

❖ ការវិភាគនិងព្យាករអំពីតម្រូវការធនធានមនុស្សត្រូវអនុលោមតាមសេចក្តីណែនាំលេខ២០ អយក.សណន ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំលេខ៤៩៨ មស.សណន ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេនគ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅតាមគ្រឹះស្ថាន បឋមសិក្សាសាធារណៈរបស់ក្រសួងមុខងារសាធារណៈ

❖ គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិកគ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញមិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងពេលអនាគតគ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីធានាថាបុគ្គលិក/គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមកនឹងបំពេញនូវតម្រូវការធនធានមនុស្សសម្រាប់ពេលបច្ចុប្បន្ន និងមិននៅសល់ក្នុងពេលអនាគត។

២.៣.១.២ ការរៀបចំផែនការក្របខណ្ឌប្រចាំឆ្នាំ

❖ អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិត្រូវសហការគ្នាដើម្បីរៀបចំផែនការមេស្តីពីតម្រូវការនិងការផ្គត់ផ្គង់គ្រូបង្រៀន ដោយផ្អែកលើចំណោលសិស្ស

- ❖ ប្រមូលផ្តុំទិន្នន័យគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនចូលនិវត្តន៍ គ្រូបង្រៀនផ្លាស់ចេញពីក្របខណ្ឌ និងមរណជន
- ❖ រៀបចំសំណើសុំក្របខណ្ឌថ្មី គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរវេន ដើម្បីដាក់ជូនក្រសួងមុខងារសាធារណៈ
- ❖ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តត្រូវអនុវត្តដូចគ្នានឹងចំណុចខាងលើ ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និងគ្រឹះស្ថានសិក្សា។

២.៣.១.៣ ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ

- ❖ បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខណ្ឌ
- ❖ បន្តប្រឡងជ្រើសរើសក្របខណ្ឌថ្មី ទៅតាមប្រភេទក្របខណ្ឌ មុខវិជ្ជាជំនាញ
- ❖ ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្តដាច់ស្រយាល
- ❖ បន្តប្រឡងជ្រើសរើសបញ្ចូលក្របខណ្ឌចំពោះបេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត
- ❖ ការជ្រើសរើសគ្រូបន្ថែមគួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ចប់ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំងកាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន ។
- ❖ ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់
- ❖ ការប្រឡងជ្រើសរើសគ្រូក្របខណ្ឌថ្មីគួរពិនិត្យជម្រើសប្រឡងជ្រើសរើសក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះ ដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ
- ❖ ការបែងចែកក្របខណ្ឌថ្មី សម្រាប់ការប្រឡងជ្រើសរើសត្រូវរៀបចំតាមដំណាក់កាល៖

- បន្ទាប់ពីទទួលបានតួលេខសម្រាប់ការប្រឡងជ្រើសរើសក្របខណ្ឌប្រចាំឆ្នាំ ក្រសួងត្រូវប្រជុំពិនិត្យ ការបែងចែកតួលេខដាក់ញប់ឱ្យទៅដល់រាជធានី ខេត្ត នីមួយៗ ទាំងគ្រូបង្រៀនកម្រិតឧត្តម កម្រិតមូលដ្ឋាន និងបឋម-មត្តេយ្យសិក្សា ដោយផ្អែកលើស្ថានភាពខ្វះដាក់ស្តែង
- បន្ទាប់ពីទទួលបានតួលេខរួចហើយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត នីមួយៗត្រូវយកទៅ បែងចែកឱ្យទៅដល់សាលារៀនដែលកំពុងខ្វះដាក់ស្តែងតាម ប្រភេទក្របខណ្ឌនិងតាមមុខវិជ្ជាជំនាញ ចំពោះគ្រូបង្រៀនកម្រិតមូលដ្ឋាន និង កម្រិតឧត្តមដោយបញ្ជាក់ឈ្មោះសាលារៀនដែលមានតម្រូវការឱ្យបានច្បាស់លាស់ និងលើកសំណើមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបុគ្គលិក ដើម្បីសុំការសម្រេច
- បន្ទាប់ពីទទួលបានសំណើ ស្តីពីតម្រូវការគ្រូបង្រៀនរបស់រាជធានី ខេត្ត ក្រសួងត្រូវ រៀបចំប្រជុំលើកទី២ ដើម្បីពិនិត្យនិងសម្រេច ហើយបញ្ជូនត្រឡប់ទៅវិញដើម្បីអនុ វត្តសម្រាប់ការប្រឡងជ្រើសរើស។

២.៣.២ ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន

- ❖ ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពី ការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួល ចំណុចមួយចំនួនដូចខាងក្រោម)
  - ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី ខេត្ត គណៈកម្មការ ជ្រើសរើសប៉ុស្តិ៍
  - គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបាន ជ្រើសរើស ត្រូវទៅបម្រើការនៅទីនោះ
  - បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច

- ○ គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្ស ឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

**២.៣.២.១ សាលារៀនលើសគ្រូបង្រៀន**

❖ ***ករណីរាជធានីភ្នំពេញ***

- ○ អនុវត្តសាកល្បងនៅរាជធានីភ្នំពេញដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀនដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។

❖ ***ករណីខេត្តផ្សេងទៀត***

- ○ បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ
- ○ ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀន ដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ
- ○ សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេសដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង។

**២.៣.២.២ សាលារៀនខ្វះគ្រូបង្រៀន**

- ❖ ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា ដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌ ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ
- ❖ ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់ សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ❖ ការស្នើបញ្ចូលក្របខណ្ឌ (ទាំងគ្រូក្របខណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀស

វាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និង ប្រសិទ្ធភាព។

២.៣.៣ ការប្រើប្រាស់ប្រាក់ម៉ោងបន្ថែម *(អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧)*

- ❖ ម៉ោងបន្ថែមសំដៅដល់ចំនួនម៉ោងដែលគ្រូបង្រៀនបានបង្រៀន និងបំពេញការងារគរុកោសល្យ ព្រមទាំងការងារពាក់ព័ន្ធនឹងការបង្រៀនលើសពីចំនួនម៉ោងកំណត់៖
  - ○ បង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត៤៨ម៉ោងក្នុង១ខែ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈដែលសាមីជនកំពុងបំពេញការងារឬគ្រឹះស្ថានសិក្សាសាធារណៈផ្សេងទៀត
  - ○ មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត ៣២ ម៉ោង ក្នុង ១ ខែ
- ❖ គ្រឹះស្ថានសិក្សាសាធារណៈដែលអាចអនុវត្តរបបម៉ោងបន្ថែមបាន លុះត្រាតែ៖
  - ○ បានគ្រោងឥណទានថវិកាសម្រាប់របបម៉ោងបន្ថែម
  - ○ ពុំមានគ្រូបង្រៀនគ្រប់គ្រាន់ ដើម្បីបង្រៀនមុខវិជ្ជាស្របតាមនិយាមកំណត់
  - ○ ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងសាមី
  - ○ ប្រើប្រាស់របបម៉ោងបន្ថែមក្នុងរង្វង់ឥណទានថវិកាដែលផ្តល់ឱ្យតែប៉ុណ្ណោះ។
- ❖ អ្នកមានសិទ្ធិបង្រៀនម៉ោងបន្ថែម លុះត្រាតែ ៖
  - ○ ជាមន្ត្រីរាជការជាគ្រូបង្រៀន ប្រចាំគ្រឹះស្ថានសិក្សា
  - ○ ជាមន្ត្រីរាជការមិនមែនជាគ្រូបង្រៀន ដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនក្នុងគ្រឹះស្ថានសិក្សា
  - ○ មានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម

- ជាគ្រូបង្រៀនបានអនុវត្តពេញលេញការបង្រៀនតាមរបបម៉ោងកំណត់។

❖ គ្រឹះស្ថានសិក្សាសាធារណៈ ដែលមានប្រភពចំណូលប្រចាំឆ្នាំផ្ទាល់របស់ខ្លួន ពីការបង់ថ្លៃរបស់សិស្ស សកម្មភាពពាណិជ្ជកម្ម ឬអំណោយផ្សេងៗ សរុបលើសពី ៥០% នៃថវិកាប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យមានការផ្តល់ប្រាក់ម៉ោងបន្ថែមពីថវិកាជាតិឡើយ។

២.៣.៤ ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន

❖ ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូ ទោះបីតាមសហព័ទ្ធក៏ដោយ

❖ អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិន ហើយត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលត្រូវផ្លាស់ចូលទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន

❖ អនុញ្ញាតឱ្យផ្ទេរក្របខណ្ឌចេញក្រៅក្រសួង ចំនួន ៥០ នាក់ ក្នុង១ឆ្នាំ ដោយមិនគិតការផ្ទេរជាករណីដោយឡែក

❖ មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស

❖ ការផ្លាស់ប្តូរពីរាជធានី ខេត្ត ចូលអង្គភាពនានាក្រោមឱវាទ ទីស្តីការក្រសួងត្រូវឆ្លងកាត់ការប្រឡង វាស់ស្ទង់សមត្ថភាពនិងឆ្លងកាត់ការធ្វើសម្ភាសន៍ដោយផ្ទាល់ពីប្រធានអង្គភាពដែលត្រូវផ្លាស់ចូល

២.៣.៤.១ ការផ្លាស់ប្តូរតាមសហព័ទ្ធ

❖ ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់ (ចៀសវាងការរៀបការក្លែងក្លាយ)

❖ អនុញ្ញាតឱ្យផ្លាស់ប្តូរតាមសហព័ទ្ធ ចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតផ្លាស់ចូលក្នុងអង្គភាពតែមួយ

❖ គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ទ្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរបន្ទាប់ពីសាមីខ្លួនបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។

## ២.៤. របាយមុខវិជ្ជានិងម៉ោងសិក្សា

តាមឯកសារ "កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ" ដែលបានរៀបចំដោយនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ សហការជាមួយនិងអង្គការ RTI ហើយត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ បានកំណត់កម្មវិធីអប់រំកម្រិតមូលដ្ឋាន (ថ្នាក់ទី៧-៩) ដូចខាងក្រោម៖

តារាង២.៦៖ មុខវិជ្ជាកម្មវិធីសិក្សាជាតិ(កម្មវិធីសិក្សាគោលឆ្នាំ២០០៦)

| ល.រ | មុខវិជ្ជា កម្មវិធីសិក្សាជាតិ | ម៉ោង/សប្ដាហ៍ |
|---|---|---|
| ១ | ភាសាខ្មែរ | ៦ |
| ២ | គណិតវិទ្យា | ៦ |
| ៣ | វិទ្យាសាស្ត្រ | ៦ |
| ៤ | សិក្សាសង្គម | ៦ |
| ៥ | ភាសាបរទេស | ៤ |
| ៦ | អប់រំកាយ សុខភាព និងកីឡា | ២ |
| | សរុបម៉ោងកម្មវិធីសិក្សាជាតិ | ៣០ |
| | បំណិនជីវិតមូលដ្ឋាន | ២-៥ |
| សរុបម៉ោងសិក្សា | | ៣២-៣៥ |

តែបើតាមឯកសារ "ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស" ដែលបានរៀបចំដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០១៥ និងចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦បានកំណត់របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី៧ ទី៨ និងទី៩ដូចខាងក្រោម៖

តារាង២.៧៖ មុខវិជ្ជាសិក្សាតាមក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |

| | | | | |
|---|---|---|---|---|
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT) | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បៈ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ៣ | ៣ | ៣ |
| | សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | ៤០ | ៤០ | ៤០ |

## ២.៥. តួនាទី និងភារកិច្ចនាយកសាលានៅកម្ពុជា

នាយកសាលាគឺជាមនុស្សដែលទទួលបន្ទុកគ្រប់គ្រងសាលារៀន។ សាលារៀនដូចជាអង្គភាពដទៃទៀតគឺមានគោលបំណងដើម្បីធ្វើឱ្យសំរេចបាន។ គោលបំណងសំខាន់របស់សាលាគឺដើម្បីផ្ទេរចំណេះដឹងជំនាញនិងឥរិយាបថដែលចង់បានដល់សិស្ស ។ សាលារៀនត្រូវការការដឹកនាំត្រឹមត្រូវដើម្បីសំរេចគោលបំណងដែលបានកំណត់ ។ ក្នុងការសិក្សានេះនាយកសាលាគឺជាអ្នកដែលទទួលខុសត្រូវក្នុងការជម្រុញទឹកចិត្តនិងធានាដល់អ្នកក្រោមបង្គាប់ដទៃទៀតឱ្យបំពេញតួនាទីបានល្អ ជាពិសេសការផ្តល់នូវគុណភាពអប់រំ ។ នាយកសាលាក៏ទទួលខុសត្រូវចំពោះសហគមន៍ទូទៅផងដែរ (Ndyali, 2013) ។

ក្របខ័ណ្ឌសមត្ថភាពនាយកសាលារៀននៅអាស៊ីអាគ្នេយ៍ ចែកចេញជាសមត្ថភាពគោលចំនួនប្រាំ (SEAMEO, 2016)គឺ ១)គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍៖ ជាសមត្ថភាពមួយនៃការរៀបចំទិសដៅយុទ្ធសាស្ត្រសម្រាប់សាលារៀន ការសម្រេចចិត្ត និងនាំឱ្យមានការផ្លាស់ប្តូរ និងនវានុវត្តន៍ ២) ភាពជាអ្នកដឹកនាំគ្រប់គ្រង៖ ជាសមត្ថភាពនៃការគ្រប់គ្រងធនធាន និងប្រព័ន្ធសាលារៀន ការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក និងការគ្រប់គ្រងកម្មវិធីរបស់បុគ្គលិក និងការគ្រប់គ្រងកម្មវិធី និងគម្រោងនានារបស់សាលារៀនប្រកបដោយនិរន្តរភាព ៣)ភាពជាអ្នកដឹកនាំការបង្រៀន-រៀន៖ ជាសមត្ថភាពដឹកនាំក្នុងការអនុវត្តនិងការកែលម្អនូវកម្មវិធីសិក្សា បង្កើតបរិស្ថានសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល អធិការ និងវាយតម្លៃលើ

ការបំពេញភារកិច្ចរបស់គ្រូបង្រៀនក៏ដូចជាផ្តល់ជាលទ្ធផលអំពីផែនការសិក្សា ៤)ឧត្តមភាពផ្ទាល់ខ្លួន៖ ជាសមត្ថភាពគ្រប់គ្រងលើប្រសិទ្ធភាពបុគ្គលទៅលើសកម្មភាពឱ្យអស់ពីសមត្ថភាព និងលទ្ធភាពដែលអាចធ្វើទៅបាន និងបន្តការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាដើម និង ៥) ការចូលរួមពីភាគីពាក់ព័ន្ធ គឺជាសមត្ថភាពក្នុងការលើកកម្ពស់ ការចែករំលែក ការទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍសាលារៀន គ្រប់គ្រងភាពជាដៃគូ និងបណ្តាញការអប់រំ និងរក្សានិរន្តរភាពនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ។

នាយកសាលារៀនជាប្រតិភូរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាទទួលបន្ទុកអភិបាលសាលារៀន ។ ក្នុងនាមតំណាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នាយកសាលាជាប្រមុខអង្គភាព ជាតំណាងអំណាចរដ្ឋបាលដែលមានទំនួលខុសត្រូវខ្ពស់បំផុតក្នុងការចាត់ចែងការងារ ដឹកនាំគ្រប់គ្រងគ្រប់សកម្មភាពរបស់សាលារៀន ទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស និងផ្នែកទំនាក់ទំនង(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ២០១៦) ។

តាមសៀវភៅស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ដែលចេញផ្សាយដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០១៦ បានលើកឡើងថានាយកសាលាមានតួនាទីជាអាជ្ញាធរអប់រំ មន្ត្រីរដ្ឋបាល ទីប្រឹក្សាគរុកោសល្យ អធិការអចិន្ត្រៃ អ្នកចរចារ អ្នកអប់រំ អ្នកផ្តល់សេវាកម្ម អ្នកពិគ្រោះយោបល់ និងជាភ្នាក់ងារអភិវឌ្ឍសហគម៍ ។

នាយកសាលាមានភារកិច្ចចម្បងលើការងាររដ្ឋបាល ការងារបច្ចេកទេសគរុកោសល្យ និងការងារទំនាក់ទំនង ។

នៅក្នុងឯកសារស្តីពីស្តង់ដានាយកសាលារៀន ដែលចេញផ្សាយដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០១៧ បានលើកឡើងថានាយកសាលាគ្រប់គ្រងបុគ្គលិកដោយ ១)ស្វែងយល់ពីសុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលា ដោយសិក្សាពីស្ថានភាពជីវភាពរបស់គ្រូ ព័ត៌មាននានាពាក់ព័ន្ធនឹងគ្រូបង្រៀន(ប្រវត្តិ ទីកន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត និងថ្ងៃខែឆ្នាំចូលនិវត្តន៍) ២) លើកទឹកចិត្តអ្នកដែលមានស្នាដៃ ដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់ប័ណ្ណសរសើរ ៣) ណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ ៤) វាយ

តម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព ៥) បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យទទួលបានការសិក្សាបន្ថែម(ជំរុញឱ្យធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជាបង្រៀន និងគរុកោសល្យ) ៦)លើកទឹកចិត្តឱ្យមានឃេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព និង ៧)លើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ។

អភិបាលកិច្ចល្អសាលារៀននឹងធ្វើឱ្យអាកប្បកិរិយានិងឥរិយាបថក្នុងការបំពេញការងារបុគ្គលិកអប់រំមានការផ្លាស់ប្តូរពីអ្នកគ្រប់គ្រងទៅជាអ្នកបម្រើសេវា ព្រមទាំងចូលរួមលើកកម្ពស់គុណភាព ប្រសិទ្ធភាព គណនេយ្យភាព ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ និងស្ថាប័នដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។

ជាតុសំខាន់ៗនៃអភិបាលកិច្ចសាលារៀនរួមមាន ១)តម្លាភាព៖ តម្លាភាពសំដៅលើរាល់វិធាន នីតិវិធី សេចក្តីសម្រេច និងព័ត៌មានពាក់ព័ន្ធទាំងឡាយត្រូវបានបើកចំហជាសាធារណៈ ។ម៉្យាងទៀតតម្លាភាពកើតឡើងនៅពេលដែលនៅរាល់សកម្មភាព និងសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងយ៉ាងសមស្របដោយបើកចំហ មានលក្ខណៈទូលំទូលាយ និងងាយជូនដល់ប្រជាពលរដ្ឋ ២) គណនេយ្យភាព៖ អនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេចនិងអនុវត្ត ៣) នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)៖ ភាពអាចគ្រោងទុកបានសំដៅទៅលើការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើវិធានច្បាប់ច្បាស់លាស់ ។ ការមានវិធានច្បាប់ច្បាស់លាស់ និងការធ្វើសេចក្តីសម្រេចដោយផ្អែកលើវិធានច្បាប់ជាធរមាន មិនមានផ្អែកលើគំនិត ឬអំណាចបុគ្គលទេ ។ ការមាននីតិរដ្ឋ គឺជាធាតុមួយដ៏សំខាន់ចាំបាច់ដើម្បីជំរុញលើកកម្ពស់ភាពអាចគ្រោងទុកបាន និង ៤)ការចូលរួម៖ គឺជាការធ្វើឱ្យមានឥទ្ធិពលនៃគោលនយោបាយនិងវិធាន ច្បាប់លើការកំណត់អាទិភាពផែនការនិងយុទ្ធសាស្ត្រ លើសេចក្តីសម្រេច លើលទ្ធផលនៃសកម្មភាពជាក់លាក់ណាមួយ ។

## ២.៦ គោលនយោបាយស្តីពីគ្រូបង្រៀន

គោលនយោបាយស្តីពីគ្រូបង្រៀន(ចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៣) មានវិសាលភាពលើការអប់រំសាធារណៈ និងឯកជនចាប់ពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ។

### ២.៦.១ ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និង មានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម ។

### ២.៦.២ គោលបំណង

គោលនយោបាយស្តីពីគ្រូបង្រៀនមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកប ដោយប្រសិទ្ធិភាព និងភាពសក្តិសិទ្ធិ ។

### ២.៦.៣ គោលដៅ

គោលដៅនៃគោលនយោបាយគ្រូបង្រៀនគឺដើម្បីទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យ ប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន ធានាការអភិវឌ្ឍ វិជ្ជាជីវៈគ្រូបង្រៀនពេលបម្រើការងារជាប់ជាប្រចាំ និងធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការ បំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ។

### ២.៦.៤ យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណង និងទិសដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖

- ❖ ការកសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ
    - ○ ពិនិត្យឡើងវិញ កែលម្អ និងកសាងលិខិតបទដ្ឋានគតិយុត្ត
    - ○ កសាងយន្តការចាំបាច់សម្រាប់ផ្សព្វផ្សាយ អនុវត្ត គាំទ្រ ពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តគោលនយោបាយ

- ○ កសាងផែនការសកម្មភាពជាក់លាក់ និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ ។

❖ ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន

- ○ លើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម
- ○ លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន
- ○ កំណត់លក្ខណៈវិនិច្ឆ័យនិងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស
- ○ ធ្វើទំនើបកម្មស្តង់ដារកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិនិងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក ។

❖ កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន

- ○ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
- ○ បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ
- ○ កំណត់ស្វ័យភាពរបស់គ្រូបង្រៀន

❖ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- ○ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ○ ប្រែក្លាយសាលាគរុកោលសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- ○ បង្កើនគុណវុឌ្ឍិនិងបទពិសោធបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- ○ ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀនដើម្បីបន្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

❖ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

- ○ ធ្វើទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ
- ○ ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់និងតាមគោលការណ៍
- ○ លើកកម្ពស់ដំណើរការនិងនីតិវិធីនៃការជ្រើសរើសនិងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អសម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា

- ធ្វើប្រតិភូកម្មជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀននិងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធិសិក្សារបស់សិស្ស ។

❖ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ

- បណ្តុះវប្បធម៌រៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹងនិងបទពិសោធន៍ជាមួយបណ្តាញក្រុមអ្នកអប់រំ
- រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ
- រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការនិងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ ។

❖ លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារនិងរស់នៅរបស់គ្រូបង្រៀនតាមរយៈការផ្តល់បៀវត្សលាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្តជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក
- ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ
- លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស ។

❖ ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន

- ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព
- ធានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ

- ធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើស បណ្តុះបណ្តាល បំពេញការងារ និងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេសនិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ
- កំណត់និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃគ្រឹះស្ថានសិក្សាសាធារណៈ សំដៅធានាការអនុវត្តគោលការណ៍និងបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ ។

❖ ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន

- បង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន
- បង្កើតនិងប្រើប្រាស់យន្តការពិនិត្យតាមដាននិងវាយតម្លៃដើម្បីកែលម្អលទ្ធផលបំពេញការងាររបស់គ្រូបង្រៀន
- បង្កើនប្រសិទ្ធភាពការប្រើប្រាស់លទ្ធផលវាយតម្លៃការប្រតិបត្តិរបស់គ្រូបង្រៀនដើម្បីអភិវឌ្ឍសមិទ្ធិអប់រំ
- កំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចលើការគ្រប់គ្រងអភិវឌ្ឍអង្គភាព ។

## ២.៧ បញ្ហាប្រឈមនៃការអប់រំនៅតាមគ្រឹះស្ថានមធ្យមសិក្សា

តាមការពិចារណា តាមវិធីទស្សនវិជ្ជា យើងរកឃើញបញ្ហាអប់រំនៅគ្រឹះស្ថានសិក្សាមួយចំនួនដូចខាងក្រោម( ស៊ន សេងហុក ២០១៩) ៖

### ២.៧.១ បញ្ហាប្រឈមពាក់ព័ន្ធការអនុវត្តគោលនយោបាយ

នៅពេលបច្ចុប្បន្ននេះ ប្រព័ន្ធអប់រំកម្ពុជាមានការរីកចម្រើនខាងបរិមាណគួរជាទីមោទនៈជាពិសេសនៅកម្រិតបឋមសិក្សា។ ទោះបីជាយ៉ាងនេះក្តី បញ្ហាសិស្សបោះបង់ការសិក្សា និងគុណភាពសិក្សានៅតែជាក្តីកង្វល់នៅឡើយ។ ជាក់ស្តែងអត្រាពិតនៃការសិក្សានៅបឋមសិក្សាមានប្រមាណ៩៧% នៅទសវត្សរ៍ចុងក្រោយនេះ។ ប៉ុន្តែសិស្សដែលអាចបញ្ចប់ការសិក្សានៅបឋមសិក្សាមានប្រមាណ៨០% បញ្ចប់មធ្យម

សិក្សា បឋមភូមិមានប្រមាណ៤០% និងមធ្យមសិក្សាទុតិយភូមិមានប្រមាណ២០% បើផ្អែកតាម គោលនយោបាយជាតិ ស្តីពីការអប់រំពេញមួយជីវិត។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិគឺ៥៩,២ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨គឺស្ថិតក្រោម៥ ភាគរយ នៃអត្រារួមនៃការសិក្សាក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិគឺ៤៦,៥ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ធៀបនឹង ៤៤,៦ ភាគរយ ចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ។ ការបោះបង់ការសិក្សាគឺជាបញ្ហាប្រឈមនៅមធ្យមសិក្សាបឋមភូមិ ពោលគឺមានកុមារជិត២០ ភាគរយ បានបោះបង់ការសិក្សានៅឆ្នាំសិក្សា២០១៧-២០១៨ ។ អត្រាបោះបង់ការសិក្សាមានការប្រែប្រួលពីស្រុកមួយទៅស្រុកមួយទៀត ពោលគឺចាប់ពី២១,៩ ភាគរយដល់៣៤,២ ភាគរយ នៅឆ្នាំសិក្សា២០១៧-២០១៨។ អត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ពិសេសនៅថ្នាក់ទី ១២(៣៨,៦ ភាគរយ)។ ការកត់សម្គាល់ឃើញថា ក្នុងចំណោមសិស្សប្រុសពីរនាក់នៅតំបន់ ជនបទ មានសិស្សម្នាក់បានបោះបង់ការសិក្សាមុនពេលបញ្ចប់ថ្នាក់ចុងក្រោយនៃមធ្យមសិក្សា ទុតិយភូមិ ។ ការវាយតម្លៃថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាក៏បានបង្ហាញផងដែរថាសិស្សស្ទើរតែពាក់កណ្តាលដែលបានចូលរួមក្នុងការវាយតម្លៃនៅថ្នាក់ទី៣ ទី៦ និងទី៨ មិនទទួលបានចំណេះដឹងដូចការរំពឹងទុកនោះទេ ។ លទ្ធផលប្រឡងថ្នាក់ជាតិសម្រាប់បញ្ចប់មធ្យមសិក្សាទុតិយភូមិបានបង្ហាញពីនិន្នាការគួរឱ្យព្រួយបារម្ភ។ ភាគរយសិស្សប្រឡងជាប់ថ្នាក់ទី១២ ដែលមានកម្រិតខ្ពស់រហូតទៅដល់ ៨៦,៨ ភាគរយ ឆ្នាំសិក្សា២០១៣-២០១៤ បានថយមកត្រឹម ៤០,៦ ភាគរយ ឆ្នាំសិក្សា ២០១៣-២០១៤ និងបានកើនដល់៦៧,០៧ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨។ ភាគរយប្រឡងជាប់មានកម្រិតទាបប៉ុន្មានឆ្នាំចុងក្រោយ ដោយសារតែការធ្វើកំណែទម្រង់ការប្រឡងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ២.៧.២ បញ្ហាប្រឈមពាក់ព័ន្ធគ្រឹះស្ថានសិក្សា

តាមការសង្កេត និងការត្រួតពិនិត្យនៅតាមសាលារៀន ព្រមទាំងការផ្តល់បទសម្ភាសពីនិស្សិត វគ្គនាយកក្នុងឆ្នាំសិក្សា២០១៨ និងឆ្នាំ២០១៩ ដែលទទួលបានការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ បានរកឃើញបញ្ហាប្រឈមនៃការអប់រំតាមសាលាវិទ្យាល័យ និងអនុវិទ្យាល័យមួយចំនួនដូចខាងក្រោម៖

**ក.បញ្ហាប្រឈមពាក់ព័ន្ធការសិក្សារបស់សិស្សមាន៖** សិស្សមិនចង់រៀន និងធ្លាក់មធ្យមភាគច្រើន សិស្សភ្លើតភ្លើនតាមសម្ភារនិយម ការគ្រប់គ្រងវិន័យសិស្សមានការធ្លាក់ចុះ ការសេពគប់មជ្ឈដ្ឋានខាងក្រៅ(គ្រឿងញៀន..) សិស្សមិនមានទំនួលខុសត្រូវក្នុងកិច្ចការសាលារបស់ខ្លួន សិស្សអវត្តមានច្រើន(ជួយធ្វើការឪពុក ម្តាយ ជួយរកកម្រៃផ្គត់ផ្គង់ជីវភាពគ្រួសារ) សិស្សបោះបង់ការសិក្សាច្រើន(រៀបការ ចំណាកស្រុក ធ្វើការរោងចក្រ សំណង់.....) សិស្សទី៦ ឡើងទី៧ ខ្សោយអំណាន និងសំណេរ ហើយនៅតំបន់ជនបទ និងដាច់ស្រយាលខ្វះផ្ទះគ្រូ(គ្រូមួយចំនួនមានទីលំនៅឆ្ងាយ) ។

**ខ.បញ្ហាប្រឈមពាក់ព័ន្ធការបំពេញភារៈកិច្ចរបស់គ្រូបង្រៀន** ៖ មិនមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង គ្រូមួយចំនួនមិនបានដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ ហើយបង្រៀនសិស្សដោយគ្មានកិច្ចតែងការបង្រៀន វិន័យធូររលុង គ្មានយុទ្ធសាស្ត្រក្នុងការទប់ស្កាត់សិស្សរៀនយឺត មិនមានការស្រាវជ្រាវបន្ថែម គ្មានគំនិតច្នៃប្រឌិត ផ្នត់គំនិតនៅបុរាណ គ្រូត្រូវបង្រៀនពីរពេល មិនសូវមានពេលទំនេរដើម្បីស្រាវជ្រាវ គ្មានមនសិការវិជ្ជាជីវៈ និងមិនយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្ស ។

**គ. បញ្ហាប្រឈមពាក់ព័ន្ធនឹងសាលារៀនរួមមាន៖** សាលាគ្មានសម្ភារឧបទ្ទេសគ្រប់គ្រាន់សម្រាប់ដំណើរការបង្រៀននិងរៀន សិស្សច្រើនលើសនិយាម បរិស្ថានសាលាមិនស្អាត គ្មានភាពទាក់ទាញ ខ្វះបង្គន់អនាម័យ ឬបង្គន់ប្រើមិនបាន ខ្វះស្វ័យវាយតម្លៃដោយនាយកសាលាមិនបានអនុវត្តតួនាទីជាអធិការអេចិន្រ្តៃយ៍ សហគមន៍មិនចូលរួម។ កង្វះគ្រូបង្រៀនពិសេសគ្រូទុតិយភូមិនៅសាលាជនបទ(សាលាខ្លះគ្រូលើសតែឯកទេសមួយចំនួនខ្វះគ្រូ) ខ្វះអគារសិក្សា ខ្វះបន្ទប់រៀន អាគារសិក្សាមួយចំនួនមានសភាពទ្រុឌទ្រោម ខ្វះសៀវភៅគ្រូ និងឯកសារស្រាវជ្រាវ ខ្វះសៀវភៅ និងគ្រូបំណិនជីវិត (រោងជាង កសិកម្ម សិល្បៈ កុំព្យូទ័រ) បណ្ណារក្សភាគច្រើនមិនបានឆ្លងកាត់វគ្គបំប៉នការងារបណ្ណាល័យ ខ្វះបណ្ណាល័យ ខ្វះសៀវភៅ និងឯកសារស្រាវជ្រាវ(ក្នុងបណ្ណាល័យ) ខ្វះបង្គន់អនាម័យ និងប្រភពទឹកប្រើប្រាស់ ការចូលរួមរបស់សហគមន៍មួយចំនួននៅមានកម្រិត អាណាព្យាបាលសិស្សមួយចំនួនធំមិនយកចិត្តទុកដាក់ និងតាមដានការសិក្សារបស់កូនៗ ខ្វះបន្ទប់ពិសោធន៍ សម្ភារៈពិសោធន៍ និងខ្វះគ្រូពិសោធន៍ ចំនួនសិស្សអាហារូបករណ៍ក្រី

ក្ររៀនពូកែមានចំនួនតិចបើប្រៀបធៀបនឹងសិស្សក្រីក្រមានចំនួនច្រើន ការងាររដ្ឋបាល និងគណនេយ្យមិនទាន់មានដំណើរការល្អ (គ្រូខ្វះចំណេះដឹងផ្នែកកុំព្យូទ័រ គ្រូមិនចូលចិត្តធ្វើការងារទាំងនេះ ផ្លាស់ប្តូរញឹកញាប់)និង នាយក នាយករង គ្រូបង្រៀនសាលារៀនមួយចំនួនធ្វើការមិនសូវឯកភាពគ្នា។

## ២.៨ ឫសគល់នៃបញ្ហាក្នុងការអប់រំនៅកម្ពុជា

ផ្អែកតាមការស្រាវជ្រាវ និងតាមវិធីសាស្ត្រទស្សនវិជ្ជា យើងរកឃើញបញ្ហាដូចខាងលើ។ ដើម្បីដោះស្រាយបញ្ហាខាងលើ យើងត្រូវសិក្សាអំពីឫសគល់នៃបញ្ហាចំនួន៤ដែលពាក់ព័ន្ធនឹងការផ្តល់សេវាអប់រំនៅសាលាមធ្យមសិក្សាជាមុនសិន( ស៊ន សេងហុក ២០១៩ )៖

### ២.៨.១. សេវានៅក្នុងសាលារៀនមានមិនគ្រប់

ការផ្តល់សេវាអប់រំនៅតាមសាលាមធ្យមសិក្សាមួយ ចំនួនមានភាពខ្វះចន្លោះ និងមិនបានគ្រប់គ្រាន់ទេ ដូចជា បណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់អនាម័យ កន្លែង លេង ការអប់រំកាយ និងកីឡា សិល្បៈ បន្ទប់ពិសោធន៏វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាង ស្របតាមកម្មវិធីសិក្សា"។

### ២.៨.២. សេវានៅក្នុងសាលារៀនមិនដំណើការ

សេវាមួយចំនួនក្នុងសាលារៀនមធ្យមសិក្សាមិនដំណើរការ ដូចជាបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់អនាម័យ កន្លែងលេង ការអប់រំកាយ និងកីឡា សិល្បៈ គណៈកម្មការទ្រទ្រង់សាលារៀន ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាបច្ចេកទេស បន្ទប់ពិសោធន៍ វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាង ស្របតាមកម្មវិធីសិក្សា"។

### ២.៨.៣. សេវានៅក្នុងសាលារៀនមិនឆ្លើយតបនឹងតម្រូវការ

សេវាអប់រំនៅសាលារៀនមធ្យមសិក្សា មួយចំនួនមិនឆ្លើយតបទៅនឹងអ្នកពាក់ព័ន្ធដូចជា៖ សេវាផ្តល់ព័ត៌មានអប់រំមិនបានឆ្លើយតបទៅអាណា ព្យាបាល សេវាមួយចំនួនមិនឆ្លើយតបនឹងតម្រូវការរបស់សិស្ស ដូចជា សេវាផ្តល់ប្រឹក្សា បណ្ណាល័យ បន្ទប់ ពិសោធន៍ បន្ទប់អនាម័យ កន្លែងលេង ការអប់រំកាយ និងកីឡា និងសិល្បៈ។

### ២.៨.៤. ខ្វះការវាយតម្លៃ និងកែលម្អសេវា

នាយកសាលាខ្វះការវាយតម្លៃ និងកែលម្អសេវា សាលារៀន ឱ្យមានដំណើរការរលូន និងប្រកបដោយចីរភាព។

## ២.៩. យុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហា

ដើម្បីដោះស្រាយបញ្ហាខាង លើត្រូវរំលើងឫសគល់នៃបញ្ហាទាំងនោះជាមុនសិន។ ដើម្បីឱ្យសេវានៅក្នុងសាលារៀនមានគ្រប់ ហើយដំណើរការ សេវានៅក្នុងសាលារៀនឆ្លើយតបនឹងតម្រូវការ មានការវាយតម្លៃ និងកែលម្អសេវា ដែលជាឫសគល់ នាយកសាលា គណៈគ្រប់គ្រងសាលាមធ្យមសិក្សា ត្រូវអនុវត្តតាមយុទ្ធសាស្ត្រ ដែលជាគោលការណ៍អភិបាលកិច្ចល្អសាលារៀនរួមមាន៖

**១.ការចូលរួម៖** ការសម្រេចចិត្តធ្វើអ្វីមួយ ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធជាមុនសិន។ គ្រប់សកម្មភាព និងគ្រប់សេវាទាំងអស់ក្នុងសាលារៀន នាយកសាលាត្រូវកៀគរ បញ្ចុះបញ្ចូល លើកទឹកចិត្តអ្នកពាក់ព័ន្ធមាន គ្រូបង្រៀន សិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលរបស់សិស្ស សហគមន៍ អាជ្ញាធរ ឱ្យចូលរួមពាក់ព័ន្ធការកសាងផែនការអភិវឌ្ឍន៍សាលា ការផ្តល់សេវាអប់រំដូចជាសេវារៀន និងបង្រៀន បណ្ណាល័យ អប់រំកាយនិងកីឡា សិល្បៈ បន្ទប់ទឹក បរិស្ថាន សន្តិសុខ... ។

**២.ការគោរពច្បាប់៖** គ្រប់ការសម្រេចចិត្តធ្វើសកម្មភាពដើម្បីផ្តល់សេវាអប់រំ នាយកសាលាត្រូវពិនិត្យមើលទៅលើគោលការណ៍ច្បាប់ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបច្ចេកទេសគ្រប់គ្រងបុគ្គលិក គ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ គ្រប់គ្រងសិស្ស។ លើសពីនេះគ្រប់ការសម្រេចចិត្តក៏ត្រូវពិនិត្យ និងពិចារណាមើលគោលនយោបាយអប់រំ ដែលជាផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តលើការងារអប់រំ។

**៣.តម្លាភាព៖** នាយកសាលា/គណៈគ្រប់គ្រង ត្រូវធ្វើការបិទផ្សាយ ចែកផ្សាយ និងផ្សព្វផ្សាយរាល់ការសម្រេចចិត្តក្នុងការអនុវត្តសកម្មភាពណាមួយ ដែលគាំទ្រសេវាតម្រូវការរបស់សិស្ស។ លើសពីនេះទៀត នាយកសាលាត្រូវបែងចែកការងារ និងធ្វើការជាក្រុមសម្រាប់អភិវឌ្ឍន៍សាលារៀន។

**៤. ការព្រមព្រៀង និងឯកភាព៖** លទ្ធផលនៃការសម្រេចចិត្តត្រូវមានការព្រមព្រៀង និងឯកភាព តាមបែបប្រជាធិបតេយ្យ ដោយអនុវត្តតាមមតិភាគច្រើន ដោយស្របតាមគោលការណ៍ច្បាប់ និងក្របខណ្ឌគោលនយោបាយ។

**៥.គណនេយ្យភាព៖** គឺជាបិតានៃការទទួលខុសត្រូវ។ នាយកសាលា/គណៈគ្រប់គ្រង ត្រូវបែងចែក ឱ្យមានការទទួលខុសត្រូវតាមលំដាប់ថ្នាក់ប្រជុំត្រួតពិនិត្យតាមដានរាល់គ្រប់សកម្មភាពការងារដែលបានចាត់ចែង ហើយនាយកត្រូវមានខ្សែគណនេយ្យភាពចំពោះការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា និងមានខ្សែគណនេយ្យភាព ចំពោះថ្នាក់ក្រោម និងប្រជាពលរដ្ឋ។

**៦. ប្រសិទ្ធភាពនិងភាពសក្តិសិទ្ធ៖** គ្រប់ការបែងចែក ការចាត់ចែងទាំងអស់ ត្រូវធ្វើ ហើយធ្វើឱ្យត្រូវ ធ្វើឱ្យលឿន ធ្វើឱ្យអស់ថវិកាតិច។

**៧.ភាពឆ្លើយតប៖** គ្រប់សេវាទាំងអស់ ត្រូវរៀបចំឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស គ្រូបង្រៀន និងអ្នកពាក់ព័ន្ធ។ តែព័ត៌មានអប់រំ ត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល។

**៨.បរិយាបន្ន៖** គ្រប់សេវានៅក្នុងសាលារៀន ត្រូវដាក់បញ្ចូលសកម្មភាពប្រកបដោយសមធម៌។

សរុបសេចក្តីមក ដើម្បីដោះស្រាយបញ្ហា ត្រូវដោះតាមយុទ្ធសាស្ត្រ៨ចំណុចខាងលើ ដែលជាគោលការណ៍អភិបាលកិច្ចល្អក្នុងសាលារៀន។ ជាពិសេសការដោះស្រាយ ត្រូវផ្អែកតាមគោលនយោបាយ និងច្បាប់ ។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. គម្រោងវិភាគ

អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របែបចម្រុះមានទាំងបែបបរិមាណវិស័យ និង បែបគុណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១ ។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រងសំណួរដែលមានសំណួរបែបទម្រង់បិទនិងទម្រង់បើកដើម្បីប្រមូល ទិន្នន័យពីគណៈគ្រប់គ្រងនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ៧៤ ក្នុងខេត្តស្វាយរៀង។ កម្រងសំណួរដែលត្រូវយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះគឺសម្រាប់បំពេញដោយនាយក នាយិការបស់សាលា ។

## ៣.២. ការប្រមូលទិន្នន័យ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមដែលចេញដោយនាយកវិទ្យាស្ថានជាតិអប់រំ ទៅសុំការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីចុះប្រមូលទិន្ន័យនៅតាមសាលារៀនគោលដៅ ។ ដោយពេលវេលានៃការស្រាវជ្រាវមានរយៈពេលខ្លី អ្នកស្រាវជ្រាវបានទាក់ទងទៅនាយកសាលានីមួយៗដោយផ្ទាល់តាមទូរសព្ទ ដើម្បីសុំការអនុញ្ញាតពីគាត់ក្នុងការប្រមូលទិន្នន័យ ។ អ្នកស្រាវជ្រាវបានស្កេន(Scan)លិខិតឧទ្ទេសនាមរួចផ្ញើជូននាយកសាលាមធ្យមសិក្សាទាំងអស់ដែលត្រូវប្រមូលទិន្នន័យតាមប្រព័ន្ធTelegram រួមទាំងកម្រងសំណួរសម្រាប់សម្ភាសគាត់ផងដែរ ។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យតាមបែប បរិមាណវិស័យ និងគុណវិស័យ ។ កម្រងសំណួរនេះគឺសម្រាប់នាយក/នាយិកា ។ កម្រងសំណួរនេះត្រូវបានបង្កើតឡើង ដោយផ្អែកលើទ្រឹស្តីនានាទាក់ទងនឹងនិយាមប្រើប្រាស់គ្រូបង្រៀន ការគ្រប់គ្រងគ្រូ ការប្រើប្រាស់គ្រូបង្រៀន មានដូចជាសេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិក ស្តង់ដានាយកសាលារៀន សៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ និង សំណួរមួយចំនួនទៀត ។ កម្រងសំណួរត្រូវបានបង្កើតតាមប្រព័ន្ធ

Online ដោយប្រើប្រាស់ Google Form រួចផ្ញើជូននាយកសាលាតាម Telegram ។ តែចំពោះសាលាដែលមិនអាចឆ្លើយតាមប្រព័ន្ធ Online បាន អ្នកស្រាវជ្រាវចុះទៅធ្វើការសម្ភាសប្រមូលទិន្នន័យដោយផ្ទាល់ ។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតជាក់លាក់ ។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមអនឡាញនិង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើគឺមានកម្រិតចង្អុលបង្ហាញចំនួន៣កម្រិត ។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺគេនិយមចូលចិត្តប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀនរបស់គណៈគ្រប់គ្រងសាលារៀន ។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរមាន៣កម្រិតពីទាប ទៅខ្ពស់ ។ រូបមន្តនៃកម្រិតមានដូចខាងក្រោម៖

១ គឺ អនុវត្តបានកម្រិតមធ្យម

២ គឺ អនុវត្តបានកម្រិតល្អបង្គួរ

៣ គឺ អនុវត្តបានកម្រិតល្អ

ការបកស្រាយលើការគណនាពិន្ទុពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម( Best, 1981)៖

$$\frac{Highest\ Score - Lowest\ Score}{Number\ of\ Level} = \frac{3-1}{3} = 0.66$$

តារាង៣.១៖ ពិន្ទុមធ្យមភាគនៃសូចនាករ

| | | |
|---|---|---|
| 1 – 1.66 | មានន័យថា | មធ្យម |
| 1.67 – 2.33 | មានន័យថា | ល្អបង្គួរ |
| 2.34 – 3 | មានន័យថា | ល្អ |

## ៣.៤. ការជ្រើសរើសគំរូសំណាក

អ្នកស្រាវជ្រាវជ្រើសរើសយកសំណាកចំនួន៧៤សាលាមធ្យមសិក្សាដែលត្រូវជា១០០% នៃចំនួនសាលាមធ្យមសិក្សាក្នុងខេត្តស្វាយរៀងដើម្បីប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវ ដោយក្នុងនោះវិទ្យាល័យចំនួន២០ សាលានិងអនុវិទ្យាល័យចំនួន ៥៤សាលា។

អ្នកស្រាវជ្រាវកំណត់យកនាយកសាលាមកសម្ភាស និងបំពេញកម្រងសំណួរព្រោះនាយកសាលាជាអ្នកដែលអនុវត្តផ្ទាល់លើការងារគ្រប់គ្រង ប្រើប្រាស់គ្រូបង្រៀននៅក្នុងសាលា ។

តារាង៣.២ ៖ ចំនួនសំណាក

| ល.រ | ឈ្មោះស្រុក | ចំនួនសំណាកគណៈគ្រប់គ្រង | ផ្សេងៗ |
|---|---|---|---|
| ១ | ស្រុកកំពង់រោទិ៍ | ១១ | |
| ២ | ស្រុកចន្ទ្រា | ៦ | |
| ៣ | ក្រុងបាវិត | ៤ | |
| ៤ | ស្រុករមាសហែក | ១៧ | |
| ៥ | ស្រុករំដួល | ១០ | |
| ៦ | ស្រុកស្វាយជ្រំ | ១៥ | |
| ៧ | ស្រុកស្វាយទាប | ៨ | |
| ៨ | ក្រុងស្វាយរៀង | ៣ | |
| | សរុប | ៧៤ | |

## ៣.៥. ការវិភាគទិន្នន័យ

ចំពោះការវិភាគទិន្នន័យបែបបរិមាណវិស័យគឺវិភាគតាមក្រាហ្វ តារាង និងមធ្យមពិន្ទុដោយប្រើកម្មវិធី Microsoft Office Excel ។ លទ្ធផលនៃចម្លើយត្រូវបានរៀបទៅតាមតារាងដែលស្រង់ចេញពីកម្មវិធី Microsoft Office Excel ហើយធ្វើការវិភាគទៅលើតារាងនីមួយៗបង្ហាញជាក្រាប រកតម្លៃមធ្យម (Mean) រួចពិនិត្យមើលគម្លាតស្តង់ដា (SD) ដើម្បីពិនិត្យមើលថាតើតម្លៃមធ្យមដែលរកឃើញនោះ មានកម្រិតខុសគ្នាអាចទទួលយកបានឬទេ និងកំណត់កម្រិត (Level) នៃការអនុវត្តសកម្មភាព ។ រីឯការវិភាគទិន្នន័យបែបគុណវិស័យគឺវិភាគតាមរយៈការចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកទៅលើទស្សនៈនិង

អត្ថន័យនៃប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា រួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

## ៤.១. ការវិភាគទិន្នន័យលើកម្រងសំណួរ

### ៤.១.១ ព័តមានទូទៅរបស់អ្នកចូលរួម

តារាងទិន្នន័យ៤.១ មានបង្ហាញព័ត៌មានទូទៅរបស់នាយក ដែលជាសំណាកស្រាវជ្រាវ ទាំងអស់រួមមានព័ត៌មានលម្អិតពីភេទ និងបទពិសោធន៍ជានាយក ដូចបង្ហាញក្នុងតារាងខាងក្រោម៖

តារាង៤.១ ៖ចំនួននាយកគិតតាមភេទ អាយុ និងរយៈពេលនៃបទពិសោធន៍ជានាយក

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ភេទ | ប្រុស | 74 | 100.00% |
| | | ស្រី | 0 | 0.00% |
| | | សរុប | 74 | 100.00% |
| ២ | រយៈពេលបំពេញការងារជានាយក | ១-៥ ឆ្នាំ | 15 | 20.27% |
| | | ៦-១០ ឆ្នាំ | 20 | 27.03% |
| | | ១១-១៥ ឆ្នាំ | 24 | 32.43% |
| | | ១៦-២០ ឆ្នាំឡើង | 15 | 20.27% |
| | | សរុប | 74 | 100.00% |

តាមតារាងទិន្នន័យ៤.១ បង្ហាញថានាយកដែលបានបំពេញកម្រងសំណួរមានចំនួន៧៤ នាក់ ក្នុងនោះស្រី០នាក់ ស្មើនឹង០% និងប្រុស ៧៤នាក់ ស្មើនឹង ១០០%។ ក្នុងចំណោមនាយកទាំង៧៤នាក់ មានបទពិសោធន៍ជានាយករយៈពេលពី១-៥ឆ្នាំមានចំនួន១៥នាក់ ស្មើនឹង ២០.២៧% រយៈពេលពី៦-១០ឆ្នាំមានចំនួន ២០នាក់ ស្មើនឹង២០.២៧% រយៈពេលពី១១-១៥ឆ្នាំចំនួន២៤នាក់ ស្មើនឹង៣២.៤៣% និងរយៈពេលពី១៦-២០ឆ្នាំឡើងទៅចំនួន១៥នាក់ ស្មើនឹង២០.២៧% ។

### ៤.១.២ ទីតាំងសាលារៀន

តារាងទិន្នន័យ៤.២ មានបង្ហាញព័ត៌មានទីតាំងសាលារៀនរបស់នាយកដែលបានបំពេញកម្រងសំណួរគ្រប់គ្រង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

តារាង ៤.២៖ ទីតាំងសាលារៀនរបស់នាយកសាលាដែលបំពេញកម្រងសំណួរ

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ទីតាំងសាលា | ជនបទ | 67 | 90.54% |
| | | ទីប្រជុំជន | 7 | 9.46% |
| | | សរុប | 74 | 100.00% |

តាមតារាងទិន្នន័យ៤.២ បង្ហាញថាសាលាដែលស្ថិតនៅទីប្រជុំជនមាន ៧ សាលាស្មើនឹង៩.៤៦% និងនៅជនបទមាន ៦៧សាលា ស្មើនឹង ៩០.៥៤%។

### ៤.១.៣ ការកំណត់ពីតម្រូវការ

លទ្ធផល នៃការស្រាវជ្រាវដូចមានក្នុងតារាង ៤.៣ បានបង្ហាញថា ស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីខេត្តស្វាយរៀងទាំង ៧៤ សាលាមានចំនួន ២៤៩៩២នាក់។ តាមនិយាមសិស្សក្នុងមួយថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់នោះចំនួនថ្នាក់ នៅក្នុងសាលាគោលដៅទាំង៧៤ ត្រូវមានចំនួនសរុប ៦២៤ថ្នាក់ (២៤៩៩២ចែកនឹង ៤០) ។ តាមនិយាមសិស្សក្នុងមួយថ្នាក់ ត្រូវរៀន ៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ ១៩៩៦៨ម៉ោង(៦២៤គុណនឹង ៣២) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ១១០៩ នាក់ (១៩៩៦៨ ចែកនឹង ១៨) សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោង ក្នុងមួយសប្តាហ៍)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីសាលាទាំង ៧៤ ខាងលើ ចំនួនថ្នាក់សរុបមានត្រឹមតែ ៥៦៤ ថ្នាក់ តិចជាងចំនួនថ្នាក់គិតតាមនិយាម ៦០ ថ្នាក់ (៦២៤ថ្នាក់ ដកនឹង ៥៦៤ថ្នាក់)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់សាលាទាំង ៧៤ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។ រីឯចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន ហើយកំពុងបម្រើការងារនៅតាមអនុវិទ្យាល័យ/វិទ្យាល័យនានាក្នុងសាលាទាំង៧៤ ក្នុងខេត្តស្វាយរៀងនោះវិញ មានចំនួន ១២៤៦នាក់ ដែលច្រើនជាងតម្រូវការតាមនិយាមចំនួន១៣៧ នាក់(១២៤៦ ដក ១១០៩)មានន័យថាលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន១៣៧ នាក់ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់និងច្រើនជាងតម្រូវការ

ដែលកំពុងអនុវត្តជាក់ស្តែងចំនួន ២៤៣នាក់ (៥៦៤គុណនឹង៣២ ចែកនឹង១៨)។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះអនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងខេត្តសំណាកមានវិធីច្រើនយ៉ាងដូចជា៖ (១) បង្កើននិយាមសិស្សថ្នាក់លើសពី៤០នាក់ ឬបន្ថយចំនួនសិស្សក្រោម៤០នាក់ក្នុងមួយថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា (២) ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀន និង (៣) ជំរុញឱ្យគ្រូបង្រៀនត្រូវឯកទេសបង្រៀនជារបបម៉ោងបន្ថែម។

តារាង៤.៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | 24992 នាក់ | |
| ថ្នាក់ | 624 ថ្នាក់ | 564 ថ្នាក់ |
| ម៉ោង | 19968 ម៉ោង | 18048 ម៉ោង |
| គ្រូ | 1109 នាក់ | 1003 នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | 1246 នាក់ | |

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានក្របខ័ណ្ឌកម្រិតមូលដ្ឋានដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាបទី១ ។




ក្រាបទី១ ៖ចំនួនគ្រូតាមមុខវិជ្ជា តាមតម្រូវការ និងមានស្រាប់

ចំនួនគ្រូភាសាបរទេសដែលត្រូវការសម្រាប់អនុវិទ្យាល័យ/វិទ្យាល័យសំណាក នៃស្រុក/ក្រុងទាំង៨ នេះគិតតាមនិយាមត្រូវការ ១៣៩នាក់ ប៉ុន្តែចំនួនគ្រូភាសាបរទេសមានក្របខណ្ឌកម្រិតមូលដ្ឋាន ហើយកំពុងបម្រើការក្នុងស្រុក/ក្រុងទាំងនេះ មានរហូតដល់ ១៥៣នាក់ តែដោយឡែកចំពោះមុខវិជ្ជាគេហវិទ្យា គីអប់រំកាយកីឡា ព័ត៌មានវិទ្យា នៅខ្វះគ្រូច្រើន។ នេះសបញ្ជាក់ថា ការផ្គត់ផ្គង់ និងការបែងចែកគ្រូបង្រៀនទៅតាមអនុវិទ្យាល័យ/វិទ្យាល័យគោលដៅនៃស្រុក/ក្រុងទាំង៨ ដែលលើកយកមកសិក្សានេះ នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ពិសេសមុខវិជ្ជាជីវៈវិទ្យា ផែនដីនិងបរិស្ថានវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា និងសីលធម៌ ពលរដ្ឋ ចំនួនគ្រូលើសពីតម្រូវការជាក់ស្តែង។

បើគិតតាមក្របខណ្ឌកម្មវិធីសិក្សាថ្មី(ឆ្នាំ២០១៦) ដែលតម្រូវឱ្យសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិអនុវត្តម៉ោងបង្រៀនចំនួន៤០ ម៉ោងក្នុងមួយសប្តាហ៍វិញឃើញថា ចំនួនម៉ោងសរុបគឺ ២៤៩៦០ម៉ោង(៦២៤គុណនឹង ៤០) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ១៣៨៧ នាក់ (២៤៩៦០ ចែកនឹង ១៨) សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ ១៨ម៉ោង ក្នុងមួយសប្តាហ៍)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែង ដែលទទួលបានពីសាលាទាំង ៧៤ ខាងលើ ចំនួនថ្នាក់សរុបមានត្រឹមតែ ៥៦៤ ថ្នាក់ តិចជាងចំនួនថ្នាក់គិតតាមនិយាម ៦០ ថ្នាក់ (៦២៤ថ្នាក់ ដកនឹង

៥៦៤ថ្នាក់)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់សាលាទាំង ៧៤ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។ រីឯចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន ហើយកំពុងបម្រើការងារនៅតាមអនុវិទ្យាល័យ/វិទ្យាល័យនានាក្នុងសាលាទាំង ៧៤ ក្នុងខេត្តស្វាយរៀងនោះវិញ មានចំនួន ១២៤៦នាក់ ដែលតិចជាងតម្រូវការតាមនិយាមចំនួន៧ នាក់ (១២៥៣ ដក១២៤៦) មានន័យថាខ្វះគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ៧ នាក់ បើអនុវត្តតាមក្របខណ្ឌកម្មវិធីសិក្សាថ្មី ឆ្នាំ២០១៦ ។

តារាង៤.៤៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង (តាមក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦)

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 24992 នាក់ | |
| ថ្នាក់ | 624 ថ្នាក់ | 564 ថ្នាក់ |
| ម៉ោង | 24960 ម៉ោង | 22560 ម៉ោង |
| គ្រូ | 1387 នាក់ | 1253 នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | 1246 នាក់ | |

បើពិនិត្យទៅលើក្រាបទី២ ខាងក្រោមនេះដែលវិភាគតាមក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៥បានបង្ហាញឱ្យឃើញថាចំនួនគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ ភាសាបរទេសគណិតវិទ្យា គេហវិទ្យា អប់រំកាយ និងកីឡា និងអបជម/អវជ/ព័.វិ មានចំនួនតិចជាងតម្រូវការ ចំណែកឯមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ផែនដីវិទ្យា ប្រវត្តិវិទ្យា និង ភូមិវិទ្យាលើសពីតម្រូវការ ។




ក្រាបទី២៖ ចំនួនគ្រូតាមមុខវិជ្ជា តាមតម្រូវការ(តាមកម្មវិធីសិក្សាឆ្នាំ២០១៦) និងមានស្រាប់

ការស្រាវជ្រាវនេះ ក៏បានពិនិត្យស៊ីជម្រៅផងដែរទៅលើអថេរស្រុកនីមួយៗ ដោយសិក្សាទៅតាមក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០០៦ ហើយលទ្ធផលដូចមានបង្ហាញខាងក្រោម៖

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកទី១ (ចន្ទ្រា)

ក្នុងស្រុកទី១ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន៦ អនុវិទ្យាល័យ/វិទ្យាល័យ មានស្ថិតិសិស្សសរុបចំនួន១៤៦៨នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន៣៧ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ១១៧៤ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន៦៥នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រឹមតែ៦០នាក់សម្រាប់សាលាទាំង៦ ដែលជាចំនួនមួយខ្វះខាតមិនអាចបំពេញតាមតម្រូវការ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកទី៦មិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងស្រុកនេះ បានបង្កើននិយាមសិស្សក្នុងមួយថ្នាក់លើសពីចំនួនដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី៣៧ថ្នាក់មកនៅត្រឹមតែ៣២ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ១១៧៤ ម៉ោងមកនៅត្រឹម១០២៤ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.៥៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី១

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ១៤៦៨នាក់ | |
| ថ្នាក់ | ៣៧ថ្នាក់ | ៣២ថ្នាក់ |
| ម៉ោង | ១១៧៤ម៉ោង | ១០២៤ម៉ោង |
| គ្រូ | ៦៥នាក់ | ៥៧នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ៦០នាក់ | |

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកទី២ (កំពង់រោទិ៍)

ក្នុងស្រុកទី២ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន ១១សាលា ដែលមានស្ថិតិសិស្សសរុបចំនួន ២៦៦៩នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន៦៧ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ២១៤៤ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ១១៩នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន រហូតដល់ ១៤២នាក់សម្រាប់សាលាទាំង ១១ ដែលលើសពីតម្រូវការនៅសាលាខ្លះ តែខ្វះនៅសាលាខ្លះ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកនេះមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងស្រុកនេះ បានបង្កើននិយាមសិស្សថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី ៦៧ថ្នាក់មកនៅត្រឹមតែ ៦៤ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ២១៤៤ម៉ោងមកនៅត្រឹម ២០៤៨ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.៦៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី២

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ២៦៦៩នាក់ | |
| ថ្នាក់ | ៦៧ថ្នាក់ | ៦៤ថ្នាក់ |

| | | |
|---|---|---|
| ម៉ោង | ២១៤៤ម៉ោង | ២០៤៨ម៉ោង |
| គ្រូ | ១១៩នាក់ | ១១៤នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១៤២នាក់ | |

**៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកទី៣ (រំដួល)**

ក្នុងស្រុកទី៣ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន ១០សាលា ដែលមានស្ថិតិសិស្សសរុបចំនួន ៣០៨៧នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន ៧៧ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ២៤៧០ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ១៣៧នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន រហូតដល់ ១៦៤នាក់សម្រាប់សាលាទាំង ១០ ដែលលើសពីតម្រូវការនៅសាលាខ្លះ តែខ្វះនៅសាលាខ្លះ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកនេះមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងស្រុកនេះ បានបង្កើននិយាមសិស្សថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី ៧៧ថ្នាក់មកនៅត្រឹមតែ ៦៩ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ២៤៧០ម៉ោងមកនៅត្រឹម ២២០៨ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី៣

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៣០៨៧នាក់ | |
| ថ្នាក់ | ៧៧ថ្នាក់ | ៦៩ថ្នាក់ |
| ម៉ោង | ២៤៧០ម៉ោង | ២២០៨ម៉ោង |
| គ្រូ | ១៣៧នាក់ | ១២៣នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១៦៤នាក់ | |

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកទី៤ (រមាសហែក)

ក្នុងស្រុកទី៤ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន ១៧សាលា ដែលមានស្ថិតិសិស្សសរុបចំនួន ៥៤១០នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន១៣៥ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៤៣២០ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ២៤០នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន រហូតដល់ ២៤៣នាក់សម្រាប់សាលាទាំង ១៧ ដែលលើសពីតម្រូវការនៅសាលាខ្លះ តែខ្វះនៅសាលាខ្លះ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកនេះមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងស្រុកនេះ បានបង្កើននិយាមសិស្សថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី ១៣៥ថ្នាក់មកនៅត្រឹមតែ ១១៧ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ៤២៣០ម៉ោងមកនៅត្រឹម ៣៧៤៤ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.៨៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី៤

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៥៤១០នាក់ | |
| ថ្នាក់ | ១៣៥ថ្នាក់ | ១១៧ថ្នាក់ |
| ម៉ោង | ៤៣២០ម៉ោង | ៣៧៤៤ម៉ោង |
| គ្រូ | ២៤០នាក់ | ២០៨នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ២៤៣នាក់ | |

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកទី៥ (ស្វាយជ្រំ)

ក្នុងស្រុកទី៥ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន ១៥សាលា ដែលមានស្ថិតិសិស្សសរុបចំនួន ៦៦២១នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន ១៦៦ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៥២៩៧ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ២៩៤នាក់។ ប៉ុន្តែតាម

ស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រឹមតែ២១៦នាក់សម្រាប់សាលាទាំង ១៥ ដែលមិនគ្រប់តាមតម្រូវការ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកទី៥ នេះមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងស្រុកនេះ បានបង្កើននិយាមសិស្សថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី ១៦៦ថ្នាក់មកនៅត្រឹមតែ ១៣៩ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ៥២៩៧ម៉ោងមកនៅត្រឹមតែ ៤៤៤៨ ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.៩៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី៥

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៦៦២១នាក់ | |
| ថ្នាក់ | ១៦៦ថ្នាក់ | ១៣៩ថ្នាក់ |
| ម៉ោង | ៥២៩៧ម៉ោង | ៤៤៤៨ម៉ោង |
| គ្រូ | ២៩៤នាក់ | ២៤៧នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ២១៦នាក់ | |

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងក្រុងទី៦ (ស្វាយរៀង)

ក្នុងក្រុងទី៦ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន៣ អនុវិទ្យាល័យ/វិទ្យាល័យ មានស្ថិតិសិស្សសរុបចំនួន១៨៦៦នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន៤៧ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ១៤៩៣ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន៨៣នាក់។ ប៉ុន្តែ តាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន រហូតដល់១០៩នាក់សម្រាប់អនុវិទ្យាល័យ/វិទ្យាល័យទាំង៣ដែលជាចំនួនមួយលើសពីតម្រូវការនៅតាមសាលាខ្លះ និងខ្វះនៅតាមសាលាខ្លះ ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងក្រុងទី៦ មិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងក្រុងនេះ បានបង្កើននិយាមសិស្សក្នុងមួយ

ថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី៤៧ថ្នាក់មកនៅត្រឹមតែ ៤៦ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ១៤៩៣ម៉ោងមកនៅត្រឹម១៤៧២ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.១០៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី៦

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ១៨៦៦នាក់ | |
| ថ្នាក់ | ៤៧ថ្នាក់ | ៤៦ថ្នាក់ |
| ម៉ោង | ១៤៩៣ម៉ោង | ១៤៧២ម៉ោង |
| គ្រូ | ៨៣នាក់ | ៨២នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១០៩នាក់ | |

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកទី៧(ស្វាយទាប)

ក្នុងស្រុកទី៧ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន ៨សាលា ដែលមានស្ថិតិសិស្សសរុបចំនួន ២៤៦៧នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន៦២ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ១៩៧៤ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ១១០នាក់។ ប៉ុន្តែតាមស្ថានភាព ជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន រហូតដល់ ១១៨ នាក់សម្រាប់អនុវិទ្យាល័យ/វិទ្យាល័យទាំង ៨ ដែលលើសពីតម្រូវការនៅសាលាខ្លះ តែខ្វះនៅសាលាខ្លះ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកទី៧មិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងស្រុកនេះ បានបង្កើននិយាមសិស្សថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី ៦២ថ្នាក់មកនៅត្រឹមតែ ៥៤ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី ១៩៧៤ ម៉ោងមកនៅត្រឹម ១៧២៨ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.១១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងស្រុកទី៧

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ២៤៦៧នាក់ | |
| ថ្នាក់ | ៦២ថ្នាក់ | ៥៤ថ្នាក់ |
| ម៉ោង | ១៩៧៤ម៉ោង | ១៧២៨ម៉ោង |
| គ្រូ | ១១០នាក់ | ៩៦នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១១៨នាក់ | |

### ៤.១.៣.១ ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងក្រុងទី៨(បារិត)

ក្នុងក្រុងទី៨ សំណាកដែលត្រូវបានជ្រើសរើសមាន ចំនួន ៤សាលា ដែលមានស្ថិតិសិស្សសរុបចំនួន ១៨២១នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន៤៦ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍១៤៥៧ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន៨១នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រឹមតែ៥៦នាក់សម្រាប់អនុវិទ្យាល័យ/វិទ្យាល័យទាំង៤ ដែលមិនគ្រប់តាមតម្រូវការ។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងក្រុងទី៨មិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ជាដំណោះស្រាយចំពោះមុខ អនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងក្រុងនេះ បានបង្កើននិយាមសិស្សថ្នាក់លើសពីចំនួន ដែលកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់ជាក់ស្តែងថយចុះពី៤៦ថ្នាក់មកនៅត្រឹមតែ៤០ថ្នាក់ ចំនួនម៉ោងបង្រៀនថយចុះពី១៤៥៧ម៉ោងមកនៅត្រឹមតែ១២៨០ម៉ោងក្នុង១សប្តាហ៍ ។

តារាង៤.១២៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងនៅក្នុងក្រុងទី៨

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ១៨២១នាក់ | |
| ថ្នាក់ | ៤៦ថ្នាក់ | ៤០ថ្នាក់ |

| ម៉ោង | ១៤៧៥ម៉ោង | ១២៨០ម៉ោង |
|---|---|---|
| គ្រូ | ៨១នាក់ | ៧១នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ៥៦នាក់ | |

**៤.១.៤ ទស្សនៈរបស់គណៈគ្រប់គ្រងលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន**

តាមតារាងទិន្នន័យ៤.១៣ យើងសង្កេតឃើញថា អ្នកឆ្លើយសំណួរក្នុងកម្រិតនៃការអនុវត្តបានល្អមានចំនួនច្រើនជាងគេគឺ ៦៣.១៨% បន្ទាប់មកកម្រិតនៃការអនុវត្តបានល្អបង្គួរគឺ ៣០.២៩% និងអនុវត្តបានកម្រិតមធ្យមគឺ ៦.៥៣% ។

តារាង៤.១៣៖ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត

| **A. ការគ្រប់គ្រងគ្រូបង្រៀន** | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | |
|---|---|---|---|
| | មធ្យម | ល្អបង្គួរ | ល្អ |
| ១. លោក លោកស្រីបានស្វែងយល់ពីសុខទុក្ខរបស់គ្រូបង្រៀន ដោយសិក្សាពីប្រវត្តិ កន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត ថ្ងៃខែឆ្នាំចូលនិវត្តន៍ | 5 | 24 | 45 |
| ២. លោក លោកស្រីមានគោលការណ៍ស្នើដំឡើងកាំប្រាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ ក្នុងការលើកទឹកចិត្តបុគ្គលិកនៅក្នុងសាលា | 0 | 14 | 60 |
| ៣. លោក លោកស្រីតែងណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ | 0 | 16 | 58 |
| ៤. លោក លោកស្រីវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព | 2 | 18 | 54 |
| ៥. លោក លោកស្រីជំរុញឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជា និងគរុកោសល្យ | 0 | 24 | 50 |
| ៦. លោក លោកស្រី លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព | 6 | 18 | 50 |
| ៧. លោក លោកស្រីលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀននិងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | 0 | 15 | 59 |

| B. ការប្រើប្រាស់គ្រូបង្រៀន | | | |
|---|---|---|---|
| ៨. លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន | 21 | 26 | 27 |
| ៩. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច | 8 | 23 | 43 |
| ១០. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីបានអនុវត្តរដ្ឋបាលសិក្សាបានត្រឹមត្រូវ | 5 | 27 | 42 |
| ១១. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីវាយតម្លៃសិស្សប្រកបដោយតម្លាភាព និងប្រសិទ្ធភាព | 7 | 36 | 31 |
| ១២. លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់ | 4 | 28 | 42 |
| **ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ** | 6.53% | 30.29% | 63.18% |

តារាងទិន្នន័យ៤.១៤ ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលានៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តស្វាយរៀង ពីតម្លៃមធ្យម (Mean) តម្លៃគម្លាតស្តង់ដារ (SD) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពតាមផ្នែកទាំងពីរគឺការគ្រប់គ្រងគ្រូបង្រៀន និងការប្រើប្រាស់បង្រៀន ។

តារាង ៤.១៤៖កម្រិតនៃការអនុវត្តសកម្មភាពលម្អិតលើផ្នែកគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន

| A. ការគ្រប់គ្រងគ្រូបង្រៀន | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|
| ១. លោក លោកស្រីបានស្វែងយល់ពីសុខទុក្ខរបស់គ្រូបង្រៀន ដោយសិក្សាពីប្រវត្តិ កន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត ថ្ងៃខែឆ្នាំចូលនិវត្តន៍ | 2.54 | 0.62 | ល្អ |
| ២. លោក លោកស្រីមានគោលការណ៍ស្នើដំឡើងកាំប្រាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ ក្នុងការលើកទឹកចិត្តបុគ្គលិកនៅក្នុងសាលា | 2.81 | 0.39 | ល្អ |
| ៣. លោក លោកស្រីតែងណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាពអនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ | 2.78 | 0.41 | ល្អ |

| | | | |
|---|---|---|---|
| ៤. លោក លោកស្រីវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព | 2.70 | 0.52 | ល្អ |
| ៥. លោក លោកស្រីជំរុញឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជា និងគរុកោសល្យ | 2.68 | 0.47 | ល្អ |
| ៦. លោក លោកស្រី លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព | 2.59 | 0.64 | ល្អ |
| ៧. លោក លោកស្រីលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀននិងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | 2.80 | 0.40 | ល្អ |
| សរុប | 2.70 | 0.49 | ល្អ |
| **B. ការប្រើប្រាស់គ្រូបង្រៀន** | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិត |
| ៨. លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន | 2.08 | 0.81 | ល្អ |
| ៩. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច | 2.47 | 0.69 | ល្អ |
| ១០. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីបានអនុវត្តរដ្ឋបាលសិក្សាបានត្រឹមត្រូវ | 2.50 | 0.62 | ល្អ |
| ១១. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីវាយតម្លៃសិស្សប្រកបដោយតម្លាភាព និងប្រសិទ្ធភាព | 2.32 | 0.64 | ល្អ |
| ១២. លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់ | 2.51 | 0.60 | ល្អ |
| **សរុប** | 2.38 | 0.67 | ល្អ |

តាមតារាងទិន្នន័យ៤.១៤ បានបង្ហាញពីមធ្យមភាគសរុបផ្នែក A៖ការគ្រប់គ្រងគ្រូបង្រៀននៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តស្វាយរៀងគឺយល់ស្របក្នុងកម្រិត“ល្អ” (មធ្យមភាគពិន្ទុ=២.៧០)។ សូចនាករ "លោក លោកស្រីមានគោលការណ៍ស្នើដំឡើងកាំប្រាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ ក្នុងការលើកទឹកចិត្តបុគ្គលិកនៅក្នុងសាលា” ទទួលបានការយល់ស្របខ្ពស់ជាងក្នុងកម្រិត “ល្អ” (មធ្យមភាគពិន្ទុ=២.៨១) និងសូចនាករ “លោក លោកស្រីបានស្វែងយល់ពីសុខទុក្ខរបស់គ្រូបង្រៀន ដោយសិក្សាពីប្រវត្តិ កន្លែងស្នាក់

នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត ថ្ងៃខែឆ្នាំចូលនិវត្តន៍" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=២.៥៤) ។

ផ្នែក B៖ការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តស្វាយរៀងគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=២.៣៨)។ សូចនាករ "លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់" ទទួលបានការយល់ស្របខ្ពស់ជាងក្នុងកម្រិត "ល្អ"(មធ្យមភាគពិន្ទុ=២.៥១) និងសូចនាករ "លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន" ទទួលបានការយល់ស្របទាបជាងគេតែស្ថិតក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគពិន្ទុ=២.០៨) ។

តារាង៤.១៥ ឆ្លុះបញ្ចាំងពីការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលាអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តស្វាយរៀង ពីតម្លៃមធ្យម (Mean) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពសរុបលើផ្នែកទាំងពីរ៖ (១)ការប្រើប្រាស់គ្រូបង្រៀន និង(២)ការគ្រប់គ្រងគ្រូបង្រៀន ។

តារាង៤.១៥៖ កម្រិតនៃការអនុវត្តសកម្មភាពលើការប្រើប្រាស់និងការគ្រប់គ្រងគ្រូបង្រៀន

| ល.រ | ស្ថានភាពនៃការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន | តម្លៃមធ្យម | កម្រិត |
|---|---|---|---|
| 1 | ការគ្រប់គ្រងគ្រូបង្រៀន | 2.38 | ល្អ |
| 2 | ការប្រើប្រាស់គ្រូបង្រៀន | 2.70 | ល្អ |
| | សរុប | 2.54 | ល្អ |

តាមតារាងទិន្នន័យ៤.១៥ បានបង្ហាញពីមធ្យមភាគសរុបនៃការគ្រប់គ្រងនិងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តស្វាយរៀងគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=២.៥៤) ។ ផ្នែក A៖ការគ្រប់គ្រងគ្រូបង្រៀនទទួលបានការយល់ស្របទាបជាងគេតែក្នុងកម្រិតល្អ(មធ្យមភាគពិន្ទុ=២.៣៨) និងផ្នែក B៖ការប្រើប្រាស់គ្រូបង្រៀនទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិតល្អ(មធ្យមភាគពិន្ទុ=២.៧០) ។

អ្នកស្រាវជ្រាវរកឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អមួយចំនួនតាមរយៈតារាងខាងលើនេះ ។ នាយកសាលាមានការគ្រប់គ្រងគ្រូបង្រៀនបានល្អដោយពួកគាត់បានអនុវត្តការគ្រប់គ្រងគ្រូបង្រៀនបានស្របទៅតាមស្តង់ដាទី៤ នៃស្តង់ដានាយកសាលាដែលបានលើកឡើងថានាយកសាលាត្រូវមានភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន។ ការគ្រប់គ្រងរដ្ឋបាលសាលារៀនជាភារកិច្ចសំខាន់មួយរបស់អ្នកដឹកនាំក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកគុណភាព និងប្រសិទ្ធភាពដើម្បីធ្វើការវាស់ស្ទង់ និងដោះស្រាយបញ្ហាចំពោះមុខលើការរៀបចំអង្គភាពមួយដោយផ្អែកលើលិខិត បទដ្ឋានគតិយុត្តនានា សំដៅធ្វើឱ្យមានការអភិវឌ្ឍលើគ្រប់ផ្នែក ដូចជា បរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រង ហិរញ្ញវត្ថុ និយតភាពការងារ និងត្រួតពិនិត្យវាយតម្លៃ ការផ្តល់សេវា ការគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក ថ្នាក់ សិស្ស ការរៀបចំផែនការសកម្មភាព និងថវិកា ដើម្បីបង្ហាញភស្តុតាងជាក់លាក់ក្នុងការអនុវត្តអ្វីដែលថ្មីរបស់នាយកសាលារៀន។ ក្នុងការគ្រប់គ្រងបុគ្គលិកនាយកសាលាត្រូវស្វែងយល់ពីសុខទុក្ខរបស់គ្រូបង្រៀន ដោយសិក្សាពីប្រវត្តិ កន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណាប់ចំណូលចិត្ត ថ្ងៃខែឆ្នាំចូលនិវត្តន៍ មានគោលការណ៍ស្នើដំឡើងកាំប្រាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ ក្នុងការលើកទឹកចិត្តបុគ្គលិកនៅក្នុងសាលា ណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព ជំរុញឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជា និងគរុកោសល្យ លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព លើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀននិងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ។

ចំណែកការប្រើប្រាស់គ្រូបង្រៀនវិញនាយកសាលាក៏អនុវត្តបានល្អដែរដោយពួកគាត់បានរៀបចំគ្រូបង្រៀនចំឯកទេសឱ្យអស់លទ្ធភាពរួច ទើបគាត់យកគ្រូដែលខុសឯកទេសទៅជួយបង្រៀនដើម្បីឱ្យសាលារបស់គាត់អាចដំណើរការបង្រៀន និងរៀនបាន ។ នាយកសាលាតែងចុះអធិការកិច្ចគ្រូបង្រៀនជាប្រចាំដើម្បីជាចំណែកមួយដ៏សំខាន់សម្រាប់ការវាយតម្លៃគុណភាពអប់រំរបស់សាលា និងដើម្បីពង្រឹងលើការបំពេញការងាររបស់គ្រូបង្រៀន។ ចំណែកឯគ្រូបង្រៀននៅសាលាទាំងនោះភាគច្រើនគឺយកចិត្តទុកដាក់ក្នុង

ការបំពេញការងារដោយគាត់បានមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច អនុវត្តរដ្ឋបាលសិក្សាបានត្រឹមត្រូវ និងមានមនសិការវិជ្ជាជីវៈជាគ្រូបង្រៀន ។

ជារួមបើពិនិត្យលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិរបស់នាយកសាលាក្នុងខេត្តស្វាយរៀងមានប្រសិទ្ធភាពគួរឱ្យកត់សម្គាល់ ។ នាយកសាលាបានប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តិ សេចក្ដីណែនាំនានាសម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅតាមសាលារបស់ខ្លួន ។

### ៤.១.៥ បញ្ហាប្រឈមនិងដំណោះស្រាយរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន

#### ក. បញ្ហាប្រឈមលើការប្រើប្រាស់គ្រូបង្រៀន

ចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន ក្នុងចំណោមនាយកសាលាទាំង៥៧នាក់ ភាគច្រើនបានលើកឡើងថា សាលារបស់គាត់ខ្វះគ្រូបង្រៀនធ្វើឱ្យពិបាកក្នុងការរៀបចំសិស្សឱ្យរៀនត្រូវតាមនិយាមកំណត់របស់ក្រសួង មានគ្រូមិនគ្រប់ឯកទេស ឯកទេសខ្លះគ្រូច្រើនលើសពីតម្រូវការ ការផ្ដល់គ្រូមកឱ្យសាលាពីសំណាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្តមិនត្រូវតាមតម្រូវការ គ្រូមានកន្លែងរស់នៅឆ្ងាយពីសាលារៀន គ្រូតាមឯកទេសមានមិនគ្រប់ ពិបាកក្នុងការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ គ្រូម្នាក់បង្រៀនពីរមុខវិជ្ជាឬច្រើនជាងនេះ គ្រូខ្លះបំពេញការងារមិនបានពេញលេញតាមការចាត់តាំង គ្រូមួយចំនួនតូចមកបង្រៀនយឺតម៉ោងនិងពុំមាន កិច្ចតែងការបង្រៀនបានទៀងទាត់ប្រចាំសប្ដាហ៍ គ្រូមួយចំនួនខ្វះមនសិកាមានប្រយោជន៍ផ្ទាល់ខ្លួនបានធ្វើ គ្រូខ្វះចំណេះដឹងផ្នែក ICT និងប្រព័ន្ធអេឡិចត្រូនិច ។

លទ្ធផលខាងលើបង្ហាញថាបញ្ហាប្រឈមដែលកើតមានឡើងក្នុងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិគឺដោយសារក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ធ្វើការបែងចែក និងផ្ដល់គ្រូបង្រៀនទៅតាមគ្រឹះស្ថានមធ្យមសិក្សាមិនបានគ្រប់គ្រាន់តាមឯកទេស និងមិនបានត្រូវតាមតម្រូវការ ។ សាលាខ្លះដែលស្ថិតនៅទីប្រជុំជន គឺមានគ្រូបង្រៀនលើសពីតម្រូវការ

ចំណែកឯសាលាដែលនៅជនបទតែងតែជួបនូវបញ្ហាកង្វះគ្រូបង្រៀន ។ ចំណែក Kayode (2011) ក៏បានរកឃើញដែរថាសាលានៅទីក្រុងមានចំនួនគ្រូបង្រៀនច្រើនជាងសាលានៅទីជនបទ ដោយសាលាមធ្យមសិក្សាមួយចំនួននៅជនបទមានគ្រូបង្រៀនត្រឹមតែ៧នាក់ប៉ុណ្ណោះ ដោយរាប់ទាំងនាយកសាលាផងដែរ ដូចនេះចំនួននេះមិនគ្រប់គ្រាន់សម្រាប់បង្រៀនសិស្សនោះទេ ។ បញ្ហានេះបណ្តាលមកពីការបែងចែកគ្រូបង្រៀនទៅតាមសាលាមិនទាន់មានភាពឆ្លើយតបទៅនឹងតម្រូវការ ។

## ខ. ដំណោះស្រាយចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងការប្រើប្រាស់គ្រូបង្រៀននៅសាលារបស់ខ្លួន នាយកសាលាភាគច្រើនបានចាត់តាំងគ្រូមុខវិជ្ជាផ្សេងទៅបង្រៀនមុខវិជ្ជាដែលខ្វះគ្រូ ដោយយកគ្រូផ្នែកវិទ្យាសាស្ត្រឱ្យជួយបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយគ្រូផ្នែកសង្គមជួយបង្រៀនផ្នែកសង្គម យកមន្ត្រីការិយាល័យទៅជួយបង្រៀន ជ្រើសរើសគ្រូដែលមានបទពិសោធបង្រៀនច្រើនឆ្នាំ មានចំណេះដឹងទូលំ-ទូលាយ និងធ្វើការបំប៉នជាប្រចាំតាមរយៈការប្រជុំក្រុមបច្ចេកទេស១ខែម្តង រៀបចំកាលវិភាគបង្រៀនជាក់ស្តែង គ្រូម្នាក់បង្រៀន២ឬ៣ឬ៤ មុខវិជ្ជា ជំរុញឱ្យគ្រូបង្រៀនខិតខំស្រាវជ្រាវ( ទាំងមុខវិជ្ជាឯកទេសនិងមិនមែនឯកទេស) ឱ្យគ្រូបង្រៀនជាលក្ខណៈម៉ោងបន្ថែមទៅតាមឯកទេសដែលខ្វះគ្រូ ហៅគ្រូដែលបំពេញការងារមិនបានល្អមកជួបប្រជុំដោះស្រាយបញ្ហានៃការបំពេញការងារ ប្រជុំ ណែនាំ លើកទឹកចិត្តបុគ្គលិកឱ្យគោរពពេលវេលា ដោយយោងទៅលើសេចក្តីណែនាំរបស់ក្រសួងអប់រំលេខ ៥៦ អយក ចំពោះសាលាដែលខ្វះបន្ទប់គឺខ្ចីបន្ទប់ និងខ្ចីគ្រូពីក្រៅក្នុងការបង្រៀនចំពោះវិទ្យាល័យមួយចំនួនគឺយកគ្រូឧត្តមជួយបង្រៀនបឋមភូមិ និងយកគ្រូមូលដ្ឋានដែលលើសនៅផ្នែកបឋមភូមិឱ្យជួយបង្រៀនផ្នែកទុតិយភូមិ។ បើតាមការសិក្សារបស់ Ibadin (2010) បានបង្ហាញថាគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងទីក្រុងមានបន្ទុកការងារប្រចាំសប្តាហ៍ជាមធ្យម១៦ ម៉ោងខណៈពេលដែលគ្រូបង្រៀននៅតាមជនបទរបស់ពួកគេមាន២៦ ម៉ោង។ គ្រូអនុវិទ្យាល័យនៅតាមជនបទមិនត្រឹមតែត្រូវបានប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវបានប្រើប្រាស់ច្រើនជាងគ្រូអនុវិទ្យាល័យនៅតាមទីក្រុង ។

### ៤.១.៦ មតិយោបល់បន្ថែមរបស់នាយកសាលាលើការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន

នាយកសាលាភាគច្រើនបានផ្តល់គំនិតយោបល់ក្នុងការគ្រប់គ្រងគ្រូបង្រៀនថាជាការបែងចែកភារកិច្ចបុគ្គលិកទៅតាមឯកទេស សមត្ថភាព និងបទពិសោធន៍ការងារ ប្រជុំត្រួតពិនិត្យ វាយតម្លៃសកម្មភាពការងារ និងកែលម្អទាន់ពេល ចុះវត្តមានបុគ្គលិកទៀងទាត់ មានការលើកសរសើរ ផ្តល់ឱកាសនិងលើកទឹកចិត្តអ្នកសិក្សាបន្ត និងឧស្សាហ៍ព្យាយាមក្នុងការងារ ស្តីបន្ទោស ឬប្រើវិធានការរដ្ឋបាលរបស់ក្រុមប្រឹក្សាវិន័យបុគ្គលិកចំពោះគ្រូអសកម្មការងារ ។ ការគ្រប់គ្រងគ្រូបង្រៀនត្រូវផ្អែកតាមគោលការណ៍ច្បាប់ជាធំ មានលិខិតបទដ្ឋានគតិយុត្តិដោយរៀបចំរចនាសម្ព័ន្ធការងារច្បាស់លាស់ ។ ដោះស្រាយបញ្ហាដោយយុត្តិធម៌ តម្លាភាព និងតាមលក្ខណៈជាក់ស្តែង នាយកមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀន ដោយស្វែងយល់ពីគ្រូ លើកទឹកចិត្តគ្រូ ។ ចំនុចសំខាន់គឺត្រូវ ធ្វើឱ្យលោកគ្រូអ្នកគ្រូ យល់ច្បាស់ពី តួនាទីនិងភារកិច្ចរបស់ខ្លួន តាមរយៈផែនការដែលបានដាក់ជូនប្រចាំសប្តាហ៍ និងប្រចាំខែ។

ចំពោះការប្រើប្រាស់គ្រូបង្រៀនវិញនាយក បានលើកឡើងថាប្រើប្រាស់គ្រូអនុវត្តទៅតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាឱ្យអស់លទ្ធភាព ទើបយកគ្រូដែលខុសឯកទេសទៅជួយបង្រៀនដើម្បីដោះស្រាយឱ្យសាលាអាចដំណើរការទៅបានរលូន តែមុននិងយកគ្រូដែលខុសឯកទេសទៅជួយបង្រៀនគឺត្រូវពិនិត្យកម្រិតយល់ដឹងរបស់គាត់ជាមុនសិនដើម្បីចាត់តាំងឱ្យទៅបង្រៀនមុខវិជ្ជាដែលខ្វះនោះបានលទ្ធផលល្អ។ ការប្រើប្រាស់គ្រូបង្រៀនយោងទៅលើកត្តាបីរួមមាន មនសិកា ជំនាញឬឯកទេសវិជ្ជាជីវៈ និងក្រមសីលធម៌។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ស្នាដៃស្រាវជ្រាវនេះបានបង្ហាញនូវលទ្ធផលធំៗពីរគឺស្ថានភាពនៃការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង និងបញ្ហាប្រឈមដែលបានកើតឡើងក្នុងការប្រើប្រាស់គ្រូបង្រៀន និងដំណោះស្រាយរបស់នាយកសាលាលើបញ្ហាប្រឈមដែលបានកើតឡើង ។

ឆ្លងតាមការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានរកឃើញថាការគ្រប់គ្រងគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀងគឺ មានលក្ខណៈល្អដោយនាយកសាលាភាគច្រើនបានអនុត្តការគ្រប់គ្រងគ្រូបង្រៀនតាមស្តង់ដារដែលកំណត់ស្តង់ដារនាយកសាលារៀនដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គឺគាត់យកច្បាប់និងសេចក្តីណែនាំនានាមកអនុវត្ត។ រីឯការប្រើប្រាស់គ្រូបង្រៀនវិញក៏មានលក្ខណៈល្អផងដែរ ដោយនាយកសាលាបានធ្វើការប្រើប្រាស់គ្រូដោយរៀបចំគ្រូឱ្យទទួលភារកិច្ច តាមដានការបំពេញការងាររបស់គ្រូ ការធ្វើអធិការកិច្ចជាប្រចាំ តែបញ្ហាដែលប្រឈមទៅលើការប្រើប្រាស់វិញនោះគឺសាលាមួយចំនួនដែលស្ថិតនៅតាមទីប្រជុំជនគឺមានចំនួនគ្រូលើសពីតម្រូវការ រីឯសាលានៅជនបទមានបញ្ហាកង្វះគ្រូឱ្យនាយកសាលាពិបាកក្នុងការរៀបចំចំនួនថ្នាក់រៀន បំណែងចែកភារកិច្ច និងកាលវិភាគ ។ ចំពោះសាលាដែលលើសគ្រូហើយមានកម្រិតទុតិយភូមិផងនោះ នាយកសាលាបានឱ្យគ្រូកម្រិតមូលដ្ឋានទាំងនោះទៅជួយបង្រៀននៅផ្នែកទុតិយភូមិ តែចំពោះសាលាដែលមានតែបឋមភូមិវិញគឺគាត់រំលែកម៉ោងសម្រាប់បង្រៀន ដោយគ្រូមួយចំនួនបង្រៀនតែ៦ ទៅ៨ ម៉ោងក្នុងមួយសប្តាហ៍ ។ បើគិតទូទាំងខេត្ត តាមទិន្នន័យពីសាលាដែលបានសិក្សាស្រាវជ្រាវគឺចំនួនគ្រូលើសចំនួន ១៣៧នាក់លើមុខវិជ្ជាជីវៈវិទ្យា ផែនដីនិងបរិស្ថានវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា និងសីលធម៌ពលរដ្ឋ ។

## ៥.២. សំណូមពរ

បើទោះបីជាលទ្ធផលដែលបានរកឃើញបង្ហាញថា ការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលាកម្រិតមធ្យមសិក្សាបឋមភូមិនៅអនុវិទ្យាល័យ/វិទ្យាល័យនានាក្នុងខេត្តស្វាយរៀង ស្ថិតក្នុងកម្រិតមួយល្អយ៉ាងណាក៏ដោយក៏អ្នកស្រាវជ្រាវ សូមលើកឡើងនូវសំណូមពរមួយ ចំនួនដើម្បីកែលម្អចំណុចខ្វះខាត

ដែលភាគីពាក់ព័ន្ធនានាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវរួមគ្នាដោះស្រាយជាប្រព័ន្ធក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

❖ ក្រសួងអប់រំ យុវជន និងកីឡា៖

- សូមបើកវគ្គបណ្ដុះបណ្ដាលដល់គណៈគ្រប់គ្រងសាលាទាំងអស់ដែលត្រូវបានតែងតាំង ពីវិធីសាស្ត្រគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀនដើម្បីឱ្យការដឹកនាំអង្គភាពសាលារៀនប្រព្រឹត្តទៅដោយភាពរលូន និងមានប្រសិទ្ធភាព
- ជ្រើសរើសគ្រូបង្រៀនទៅតាមមុខវិជ្ជាឯកទេសដែលកំពុងខ្វះឱ្យបានគ្រប់ចំនួន និងផ្ដល់ទៅសាលាដែលកំពុងជួបនូវបញ្ហាខ្វះគ្រូបង្រៀន ។

❖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត៖

- បែងចែកគ្រូបង្រៀនតាមឯកទេស ដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន។
- ស្នើដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចុះអធិការកិច្ចសាលារៀនជាប្រចាំ និងកែលម្អ ព្រមទាំងផ្ដល់អនុសាសន៍រាល់ចំណុចខ្វះខាតរបស់សាលា
- ស្នើសុំអនុញ្ញាតការផ្លាស់ចេញតែពីសាលាដែលលើសគ្រូ និងផ្ទេរចូលទៅសាលាដែលខ្វះគ្រូ

❖ គណៈគ្រប់គ្រងសាលា៖

- រៀបចំប្រើប្រាស់គ្រូបង្រៀនឱ្យមានប្រសិទ្ធភាព ដោយការរៀបចំគ្រូត្រូវឯកទេសឱ្យអស់លទ្ធភាព ទើបយកគ្រូដែលខុសឯកទេសមកជួយ តែត្រូវរៀបចំការបំប៉នគ្រូខុសឯកទេសបន្ថែមមុននឹងប្រើប្រាស់
- ពង្រឹងការងារអធិការកិច្ចឱ្យបានទៀងទាត់ ។

❖ គ្រូបង្រៀន៖

- គោរពតាមការចាត់តាំងរបស់គណៈគ្រប់គ្រងសាលា និងបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ ដើម្បីឱ្យលទ្ធផលការងារប្រកបដោយប្រសិទ្ធភាព។
- គិតប្រយោជន៍រួមជាធំ (គឺគុណភាពនៃការបង្រៀនដើម្បីបានសិស្សដែលមានគុណភាព) ។

❖ សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត៖

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើការប្រើប្រាស់គ្រូបង្រៀនក្នុងកម្រិតមធ្យមសិក្សាបឋមភូមិក្នុងសាលាមធ្យមសិក្សាក្នុងខេត្តស្វាយរៀង ហើយការប្រមូលទិន្នន័យគឺយកចេញពីទស្សនៈនាយកសាលាតែប៉ុណ្ណោះ សម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើប្រធានបទមួយចំនួនដូចខាងក្រោម៖

- សិក្សាលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅខេត្តស្វាយរៀងដដែល ឬនៅខេត្តដទៃទៀតដោយជ្រើសរើសសំណាកធំជាងនេះរួមមាននាយក នាយករង គ្រូបង្រៀននិងសិស្សជាដើម
- សិក្សាពីភាពស័ក្តិសិទ្ធិនៃការអនុវត្តការងារភាពជាអ្នកដឹកនាំនិងគ្រប់គ្រងការបង្ហាត់បង្រៀននៅគ្រឹះស្ថានសាធារណៈ ក្នុងរាជធានី/ខេត្តណាមួយដែលសមស្រប។
- សិក្សាពីស្ថានភាពនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងគ្រឹះស្ថានសាធារណៈឆ្លើយតបបរិបទកំណែទម្រង់អប់រំនៅកម្ពុជា ។

# ឯកសារយោង


1. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា ។

2. ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) *គោលនយោបាយស្តីពីគ្រូបង្រៀន* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា ។

3. ជួន ណាត (១៩៦៧) *វចនានុក្រមខ្មែរ* ភ្នំពេញ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត.

4. នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ (២០១៦) *ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

5. នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ (២០១៧) *ស្តង់ដានាយកសាលារៀន* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

6. នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ (២០០៦) *កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

7. នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (២០១៦) *ក្របខណ្ឌកម្មវិធីសិក្សា ចំណេះទូទៅនិងអប់រំបច្ចេកទេស* . ភ្នំពេញ: ក្រសួងអយក.

8. ស៊ន សេងហុក (២០១៩) *ទស្សនៈវិជ្ជា ច្បាប់ និងគោលនយោបាយអប់រំ* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ

9. សេចក្តីណែនាំលេខ២០អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើបុគ្គលិកអប់រំ

10. សេចក្តីណែនាំលេខ៥៣អយក.សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងគ្រូបង្រៀន

11. អនុក្រឹត្យលេខ១២៦.អនក្រ.បក ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

12. Best, J. W. (1981). Research in Education. Englewood Cliffs, 4th Edition ed., New York, Jersey: Prentice Hall, Inc.

13. Ibadin, V. (2010). An Analysis of Teachers' Utilization in Urban and Rural Secondary Schools in Mid-Western States of Nigeria. *European Journal of Educational Studies*, 87-92. http://nigeria-education.org/content/analysis-teachers%E2%80%99-utilization-urban-and-rural-secondary-schools-mid-western-states-nigeri-0

14. Kayode, J. D. (2011, December). Demand, Supply and Utilization of Secondary School Teachers in Kabba/Bunu District of Kogi State,Nigeria. *Mediterranean Journal of Social Sciences*, 69-77. 2. https://citeseerx.ist.psu.edu/viewdoc/download?doi=10.1.1.656.6313

15. Ndyali, H. S. (2013). *The Role of School Head in Enhancing Students' Academic Performance in Community Secondary Schools in MBEYA Urban.* Open University of Tanzania.

16. SEAMEO, I. (2016). *Success Competencies of Southeast Asian School Heads: A Learning Guide (Khmer Translation).* Quezon: SEAMEO INNOTECH.

17. IIEP (2020). "Teacher management". Retrieved from http://www.iiep.unesco.org/en/our-mission/teacher-management on the 10th of October, 2020

18. Cambridge Dictionary (2020). "Utilization". Retrieved from https://dictionary.cambridge.org/dictionary/english/utilization

# ឧបសម្ព័ន្ធ ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន
## នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តស្វាយរៀង

ខ្ញុំបាទឈ្មោះ ខូ សុខា ជានិស្សិតរៀនវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង**" ដើម្បីបំពេញលក្ខខណ្ឌក្នុងការសិក្សា។ គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះគឺស្វែងយល់ពីស្ថានភាពនៃការគ្រប់គ្រង និងដឹកនាំ នៅកម្រិតមធ្យមសិក្សាបឋមភូមិ លើការប្រើប្រាស់គ្រូបង្រៀន និងការគ្រប់គ្រងគ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ។ ការសិក្សាក៏សំដៅស្វែងរកពីមូលហេតុ និងដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ។ ទិន្នន័យដែលប្រមូលបានពីការសិក្សានេះ គឺប្រើសម្រាប់តែក្នុងការវិភាគ និងបកស្រាយទៅលើប្រធានបទស្រាវជ្រាវខាងលើតែប៉ុណ្ណោះ។ រាល់ពត៌មានរបស់លោក លោកស្រី នឹងត្រូវរក្សាទុកជាការសម្ងាត់។

អាស្រ័យហេតុនេះ សូមលោកនាយក/នាយិកា មេត្តាជួយផ្តល់ទិន្នន័យ ក្នុងកម្រងសំណួរ ដោយឆ្លើយតបទៅតាមស្ថានភាព នៃការគ្រប់គ្រង និងដឹកនាំសាលារៀន លើការអនុវត្តកិច្ចការងារប្រចាំថ្ងៃ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក លោកស្រីដែលបានចូលរួមឆ្លើយ និងបំពេញកម្រងសំណួរខាងក្រោមនេះ។

**ផ្នែក"ក" ៖ ព័ត៌មានទូទៅ**

១. ភេទ ☐ប្រុស ☐ស្រី

២. រយៈពេលបំពេញការងារជានាយក/នាយិកា........................................................

☐១-៥ ឆ្នាំ ☐៦-១០ឆ្នាំ ☐១១-១៥ឆ្នាំ ☐១៦-២០ឆ្នាំ

៣. ឈ្មោះសាលា.....................................................

៤. សាលាមានទីតាំងស្ថិតក្នុងស្រុក........................................................

និងស្ថិតក្នុងតំបន់៖ ☐ទីប្រជុំជន ☐ជនបទ

**ផ្នែក "ខ"៖ ការកំណត់ពីតម្រូវការ( សម្រាប់នាយកបំពេញ)**

១. តើសាលារបស់លោក លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?

- ថ្នាក់ទី៧៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៨៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៩៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់

២. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់?

- ចំនួនបន្ទប់រៀនសរុប.................បន្ទប់ ប្រើប្រាស់ជាក់ស្តែង.................បន្ទប់

៣ .តើគ្រូក្របខ័ណ្ឌបានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់?

- ក្របខណ្ឌ "ក" ចំនួនសរុប......................នាក់ ក្នុងនោះស្រី......................នាក់
- ក្របខណ្ឌ "ខ" ចំនួនសរុប......................នាក់ ក្នុងនោះស្រី......................នាក់

៤. តើគ្រូក្របខ័ណ្ឌ "ខ" កំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)

- ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង....................នាក់ ស្រី................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | គ្រូបង្រៀនកម្រិតមូលដ្ឋាន (ក្របខ័ណ្ឌ ខ) | ផ្សេងៗ |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិតវិទ្យា | | |
| ៤ | រូបវិទ្យា | | |
| ៥ | គីមីវិទ្យា | | |
| ៦ | ជីវៈវិទ្យា | | |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | | |
| ៨ | ប្រវត្តិវិទ្យា | | |
| ៩ | ភូមិវិទ្យា | | |
| ១០ | សីលធម៌-ពលរដ្ឋវិជ្ជា | | |
| ១១ | គេហវិទ្យា | | |
| ១២ | កុំព្យូទ័រ(ICT) | | |
| ១៣ | អប់រំកាយនិងកីឡា | | |
| ១៤ | អប់រំសិល្បៈ | | |
| ១៥ | អប់រំសុខភាព | | |

| | | | |
|---|---|---|---|
| ១៦ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

**ផ្នែក "គ" ៖ ទស្សនៈរបស់គណៈគ្រប់គ្រងលើការគ្រប់គ្រងគ្រូបង្រៀន និងប្រើប្រាស់គ្រូបង្រៀន**

សូមលោក លោកស្រីបំពេញកម្រងព័ត៌មានដោយគូសរង្វង់ជុំវិញលេខទៅតាមកម្រិតដែលលោក លោកស្រីបានអនុវត្ត ។

** សម្គាល់៖ 1 = អនុវត្តបានកម្រិតមធ្យម 2 = អនុវត្តបានកម្រិតល្អបង្គួរ 3 = អនុវត្តបានកម្រិតល្អ*

| A. **ការគ្រប់គ្រងគ្រូបង្រៀន** | **កម្រិតអនុវត្ត** | | |
|---|---|---|---|
| ១. លោក លោកស្រីបានស្វែងយល់ពីសុខទុក្ខរបស់គ្រូបង្រៀន ដោយសិក្សាពីប្រវត្តិ កន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត ថ្ងៃខែឆ្នាំចូលនិវត្តន៍ | 1 | 2 | 3 |
| ២. លោក លោកស្រីមានគោលការណ៍ស្នើដំឡើងកាំប្រាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ ក្នុងការលើកទឹកចិត្តបុគ្គលិកនៅក្នុងសាលា | 1 | 2 | 3 |
| ៣. លោក លោកស្រីតែងណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ | 1 | 2 | 3 |
| ៤. លោក លោកស្រីវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព | 1 | 2 | 3 |
| ៥. លោក លោកស្រីជំរុញឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជា និងគរុកោសល្យ | 1 | 2 | 3 |
| ៦. លោក លោកស្រី លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព | 1 | 2 | 3 |
| ៧. លោក លោកស្រីលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀននិងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | 1 | 2 | 3 |
| B. **ការប្រើប្រាស់គ្រូបង្រៀន** | **កម្រិតអនុវត្ត** | | |
| ៨. លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន | 1 | 2 | 3 |
| ៩. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច | 1 | 2 | 3 |
| ១០. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីបានអនុវត្តរដ្ឋបាលសិក្សាបានត្រឹមត្រូវ | 1 | 2 | 3 |
| ១១. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីវាយតម្លៃសិស្សប្រកបដោយតម្លា | 1 | 2 | 3 |

| | | | |
|---|---|---|---|
| ភាព និងប្រសិទ្ធភាព | | | |
| ១២. លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់ | 1 | 2 | 3 |

## ផ្នែក "ឃ"៖ បញ្ហាប្រឈម និងដំណោះស្រាយ

១. តើលោក/លោកស្រីជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះនៅក្នុងការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅសាលារៀនរបស់លោក លោកស្រី?

……………………………………………………………………………………………...

……………………………………………………………………………………………...

……………………………………………………………………………………………...

២. តើលោក/លោកស្រីមានវិធីសាស្ត្រអ្វីខ្លះដើម្បីដោះស្រាយបញ្ហាប្រឈមលើការប្រើប្រាស់គ្រូនៅសាលារៀនរបស់លោក លោកស្រី?

……………………………………………………………………………………………...

……………………………………………………………………………………………...

……………………………………………………………………………………………...

## ផ្នែក "ង"៖ មតិយោបល់បន្ថែម

សូមលោក លោកស្រីផ្តល់យោបល់បន្ថែមទៅលើដំណើរការខាងក្រោម៖

**១. ការគ្រប់គ្រងគ្រូបង្រៀន**

……………………………………………………………………………………………...

……………………………………………………………………………………………...

……………………………………………………………………………………………...

**២. ការប្រើប្រាស់គ្រូបង្រៀន**

……………………………………………………………………………………………...

……………………………………………………………………………………………...

……………………………………………………………………………………………...

*សូមអរគុណ*

*លេខទូរសព្ទនិងតេលេក្រាម ៖ 097 980 1602 / 096 853 4548*

# ឧបសម្ព័ន្ធ ខ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៤ វជអ.ផក

បន្ទុំ អ.យ.ក ខេត្តស្វាយរៀង
ចូល លេខ ៦៣៧
ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០
ម៉ោង ១០.០០

ថ្ងៃ ៧រោច ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក
"ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

លេខៈ៧៥២ អយក.មចទ.ចល

**បានថតចម្លងតាមច្បាប់ដើមនិងបញ្ជូនមកៈ**

លោកនាយក គ្រប់វិទ្យាល័យ-អនុវិទ្យាល័យ

«ដើម្បីជួយសម្រួល»

ថ្ងៃពុធ ០១ រោច ខែស្រាព ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ស្វាយរៀង ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា**

**ប្រធានស្តីទី**

សុខ_ស៊ីដេត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :១៣៧...... វជអ. ៥៨

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុជី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ជាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | សេ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន នីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ វង្សា | ស | មណ្ឌលគិរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | រួច វី | ប | សៀមរាប |
| 27✓ | ខុ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | វៃ សុជី | ប | ឧត្តរមានជ័យ |

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត សៀង សុខណ្ណា

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# ឧបសម្ព័ន្ធ គ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ២៧៧ វជអ.ឧក

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ **"ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ"** នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នួន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នួន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សូគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សូគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុជី | ប | តាកែវ |

1

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី រដ្ឋា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី រដ្ឋា | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នូវ វីរ៉ា | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាឃលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ រដ្ឋា | ស | មណ្ឌលគីរី |
| 25 | លោកបណ្ឌិត នូវ វីរ៉ា | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | រួច រី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ អង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវេជអ "ដើម្បីជ្រាបជាព័ត៌មាន"
-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវេជអ "ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារៈ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវេជអ

បណ្ឌិត.សៀង សុវណ្ណា